ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី ១៨ លេខ ៤៣ ត្រីមាសទី ០២ ឆ្នាំ ២០១៨

# រាជកិច្ច

ផ្សាយចេញពី
ទីស្តីការគណៈរដ្ឋមន្ត្រី

## សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច សារាចរ ប្រកាស

ក

## មាតិកា

### I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


០៨-០៥-២០១៨ -ព្រះរាជក្រឹត្យ នស/រកត/០៥១៨/៤៩០ ស្តីពី ការតម្លើងថ្នាក់ប្រចាំឆ្នាំ ដល់អ្នករាជការ គ.ជ.ប ចំនួន ១២ រូប នៃក្របខ័ណ្ឌមន្ត្រីបោះឆ្នោតជាន់ខ្ពស់ នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ៥១៣៩

២៣-០៥-២០១៨ -ព្រះរាជក្រឹត្យ នស/រកត/០៥១៨/៥៥៧ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ៥១៤១

២៣-០៥-២០១៨ -ព្រះរាជក្រឹត្យ នស/រកត/០៥១៨/៥៥៨ ស្តីពី ការបញ្ចប់មុខតំណែងឯកឧត្តម **ហូ ចំរើន** ពីទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលុបឈ្មោះឯកឧត្តម ចេញពីក្របខ័ណ្ឌនៃកងយោធពលខេមរភូមិន្ទ ៥១៤៧

២៣-០៥-២០១៨ -ព្រះរាជក្រឹត្យ នស/រកត/០៥១៨/៥៥៩ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ជាតួបការ ចំពោះ កងកម្លាំងប្រដាប់អាវុធ ចំនួន ០៤ រូប ៥១៤៨

២៣-០៥-២០១៨ -ព្រះរាជក្រឹត្យ នស/រកត/០៥១៨/៥៦០ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្តម លោកជំទាវ ចំនួន ០៤ រូប និងស្ថានទូត និងអង្គការ ចំនួន ០៨ ៥១៤៩

២៣-០៥-២០១៨ -ព្រះរាជក្រឹត្យ នស/រកត/០៥១៨/៥៦១ ស្តីពី ការបញ្ចប់មុខតំណែងឯកឧត្តម **ខាវ ធីរៈ** ពីឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសប៊ែលហ្ស៊ិក និងពីឯកអគ្គរាជទូតតែងតាំងប្រចាំប្រទេសអូទ្រីស ហូឡង់ លុចហ្សំបួរ និងអមសហភាពអឺរ៉ុបចូលប្រទេសវិញ ដោយត្រូវចប់អាណត្តិបេសកកម្ម និងតែងតាំងមុខតំណែងឯកឧត្តម **ឈាំ ពិសិដ្ឋ** អគ្គនាយកនៃអគ្គនាយកដ្ឋានអឺរ៉ុប អាមេរិក និងអាហ្វ្រិក មជ្ឈិមបូព៌ា ក្រសួងការបរទេស និងសហប្រតិបត្តិការ អន្តរជាតិ ជាឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសប៊ែលហ្ស៊ិក និងជាឯកអគ្គរាជទូតតែងតាំងប្រចាំប្រទេស អូទ្រីស ហូឡង់ លុចហ្សំបួរ និងអមសហភាពអឺរ៉ុប ដែលមាននិវេសនដ្ឋាននៅទីក្រុង ប្រ៊ុយសែល ប្រទេសប៊ែលហ្ស៊ិក ៥១៥០

២៣-០៥-២០១៨ -ព្រះរាជក្រឹត្យ នស/រកត/០៥១៨/៥៦២ ស្ដីពី ការបញ្ចប់មុខតំណែងឯកឧត្តម **ពេជ្រឃុន បញ្ញា** ពីឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋឥណ្ឌា និងពីឯកអគ្គរាជទូតតែងតាំងប្រចាំប្រទេសបង់ក្លាដេស ស្រីលង្កា ប៉ាគីស្ថាន និងសាធារណរដ្ឋអ៊ីស្លាមអ៊ីរ៉ង់ ចូលប្រទេសវិញ ដោយត្រូវចប់អាណត្តិបេសកកម្ម និងតែងតាំងមុខតំណែងឯកឧត្តម **អ៊ុំ ស៊ាន** រដ្ឋលេខាធិការនៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជាប្រចាំសាធារណរដ្ឋឥណ្ឌា និងជាឯកអគ្គរាជទូតតែងតាំងប្រចាំប្រទេសបង់ក្លាដេស ស្រីលង្កា ប៉ាគីស្ថាន និងសាធារណរដ្ឋអ៊ីស្លាមអ៊ីរ៉ង់ ដែលមាននិវេសនដ្ឋាននៅទីក្រុងញូវដេលី សាធារណរដ្ឋឥណ្ឌា ៥១៥១

២៣-០៥-២០១៨ -ព្រះរាជក្រឹត្យ នស/រកត/០៥១៨/៥៦៣ ស្ដីពី ការបញ្ចប់មុខតំណែងលោកជំទាវ **ជា គឹមថា** ពីឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសជប៉ុន ចូលប្រទេសវិញ ដោយត្រូវចប់អាណត្តិបេសកកម្ម និងតែងតាំង មុខតំណែងឯកឧត្តម **អ៊ឹង រចនា** អគ្គនាយកនៃអគ្គនាយកដ្ឋានអាស៊ី-ប៉ាស៊ីហ្វិក ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាឯកអគ្គរាជទូតវិសាមញ្ញ និង ពេញសមត្ថភាពនៃព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសជប៉ុន ៥១៥២

២៣-០៥-២០១៨ -ព្រះរាជក្រឹត្យ នស/រកត/០៥១៨/៥៦៤ ស្ដីពី ការបញ្ចប់មុខតំណែងលោកជំទាវ **ខួត បញ្ញា** ពីឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជាប្រចាំសាធារណរដ្ឋហ្វីលីពីនចូលប្រទេសវិញ ដោយត្រូវចប់អាណត្តិបេសកកម្ម និងតែងតាំង មុខតំណែងឯកឧត្តម **ឡេង ចាន់វីរៈ** អគ្គាធិការ នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជាប្រចាំសាធារណរដ្ឋហ្វីលីពីន ៥១៥៣

២៣-០៥-២០១៨ -ព្រះរាជក្រឹត្យ នស/រកត/០៥១៨/៥៦៥ ស្ដីពី ការបញ្ចប់មុខតំណែងឯកឧត្ដម **ឡុយ វី** ពីឯកអគ្គរាជទូតតំណាងអចិន្ត្រៃយ៍ ប្រចាំអង្គការសហប្រជាជាតិ និងប្រទេសកាណាដា ចូលប្រទេសវិញ ដោយត្រូវចប់អាណត្តិបេសកកម្ម និងតែងតាំងមុខតំណែងឯកឧត្ដម **កែ សុវណ្ណ** តំណាងអចិន្ត្រៃយ៍រងនៃស្ថានបេសកកម្មអចិន្ត្រៃយ៍នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំអង្គការសហប្រជាជាតិ និងប្រទេសកាណាដា ជាឯកអគ្គរាជទូតតំណាងអចិន្ត្រៃយ៍ ប្រចាំអង្គការសហប្រជាជាតិ និងប្រទេសកាណាដា ដែលមាននិវេសនដ្ឋាននៅ ទីក្រុងញូវយ៉ក សហរដ្ឋអាមេរិក ៥១៥៤

២៣-០៥-២០១៨ -ព្រះរាជក្រឹត្យ នស/រកត/០៥១៨/៥៦៦ ស្ដីពី ការបញ្ចប់មុខតំណែងឯកឧត្ដម **ជុំ ប៊ុនរ៉ុង** ពីឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជាប្រចាំសហរដ្ឋអាមេរិក និងពីឯកអគ្គរាជទូតតែងតាំង ប្រចាំរដ្ឋម៉ិកស៊ិកូ ចូលប្រទេសវិញ ដោយត្រូវចប់អាណត្តិបេសកកម្ម និងតែងតាំងមុខតំណែងឯកឧត្ដម **ជុំ សុន្ទរី** អនុរដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពនៃព្រះរាជាណាចក្រកម្ពុជាប្រចាំ សហរដ្ឋអាមេរិក និងជាឯកអគ្គរាជទូតតែងតាំងប្រចាំរដ្ឋម៉ិកស៊ិកូ ដែលមាននិវេសនដ្ឋាននៅ ទីក្រុងវ៉ាស៊ីនតោន សហរដ្ឋអាមេរិក ៥១៥៥

២៣-០៥-២០១៨ -ព្រះរាជក្រឹត្យ នស/រកត/០៥១៨/៥៦៧ ស្ដីពី ការបញ្ចប់មុខតំណែងឯកឧត្ដម **កេត សោផាន់** ពីឯកអគ្គរាជទូត ប្រតិភូអចិន្ត្រៃយ៍ ប្រចាំអង្គការយូណេស្កូ និងពីនាយកផ្ទះខ្មែរ (Maison du Cambodge) នៅមជ្ឈមណ្ឌលសាកលវិទ្យាល័យនៅទីក្រុងប៉ារីស ចូលប្រទេសវិញ ដោយត្រូវចប់អាណត្តិបេសកកម្ម ៥១៥៦

២៣-០៥-២០១៨ -ព្រះរាជក្រឹត្យ នស/រកត/០៥១៨/៥៦៨ ស្ដីពី ការតែងតាំងមុខតំណែងឯកឧត្ដម និងលោកជំទាវ ចំនួន ០៥ រូប ៥១៥៧

២៤-០៥-២០១៨ -ព្រះរាជក្រឹត្យ នស/រកត/០៥១៨/៥៦៩ ស្ដីពី ការតែងតាំងឯកឧត្ដម **សារឹម ប៊ុណ្ណាមី** ជាទីប្រឹក្សាក្រសួងព្រះបរមរាជវាំង មានឋានៈស្មើ រដ្ឋលេខាធិការ ៥១៥៨

២៤-០៥-២០១៨ -ព្រះរាជក្រឹត្យ នស/រកត/០៥១៨/៥៧០ ស្ដីពី ការតែងតាំងគោរមងារព្រះរាជាគណៈនៃគណៈមហានិកាយ នៅព្រះរាជាណាចក្រកម្ពុជា ចំនួន ៦២ ព្រះអង្គ ៥១៥៩

២៤-០៥-២០១៨ -ព្រះរាជក្រឹត្យ នស/រកត/០៥១៨/៥៧១ ស្តីពី ការតែងតាំង និងផ្តល់ឋានៈដល់ឯកឧត្តម **ទើង ហៀង** ជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារ មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន ៥១៦២

២៤-០៥-២០១៨ -ព្រះរាជក្រឹត្យ នស/រកត/០៥១៨/៥៧២ ស្តីពី ការតែងតាំង និងផ្តល់ឋានៈទីប្រឹក្សាក្រសួងមហាផ្ទៃ ចំនួន ០៤ រូប ៥១៦៣

២៤-០៥-២០១៨ -ព្រះរាជក្រឹត្យ នស/រកត/០៥១៨/៥៧៣ ស្តីពី ការតែងតាំងឯកឧត្តម **ឃួន សំណាង** ជាអគ្គាធិការ នៃអគ្គាធិការដ្ឋាន ក្រសួងពាណិជ្ជកម្ម ៥១៦៤

២៤-០៥-២០១៨ -ព្រះរាជក្រឹត្យ នស/រកត/០៥១៨/៥៧៤ ស្តីពី ការដាក់មន្ត្រីរាជការ ០២ រូប ឱ្យចូលនិវត្តន៍ក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ ១ នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ៥១៦៥

២៤-០៥-២០១៨ -ព្រះរាជក្រឹត្យ នស/រកត/០៥១៨/៥៧៥ ស្តីពី ការតម្លើងឋានន្តរស័ក្តិដល់នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ និងនាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ១៥ រូប ៥១៦៦

២៤-០៥-២០១៨ -ព្រះរាជក្រឹត្យ នស/រកត/០៥១៨/៥៧៦ ស្តីពី ការតម្លើងថ្នាក់ និងឋានន្តរស័ក្តិប្រចាំឆ្នាំដល់មន្ត្រីរាជការ ៤៥ រូប នៅក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ៥១៦៨

២៤-០៥-២០១៨ -ព្រះរាជក្រឹត្យ នស/រកត/០៥១៨/៥៧៧ ស្តីពី ការតម្លើងថ្នាក់ និងឋានន្តរស័ក្តិប្រចាំឆ្នាំដល់មន្ត្រីរាជការ ២៧ រូប នៅក្រសួងមុខងារសាធារណៈ ៥១៧១

២៤-០៥-២០១៨ -ព្រះរាជក្រឹត្យ នស/រកត/០៥១៨/៥៧៨ ស្តីពី និយ័តកម្មក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់ដល់លោក **ជុំ ចាន់នី** នៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ៥១៧៣

២៤-០៥-២០១៨ -ព្រះរាជក្រឹត្យ នស/រកត/០៥១៨/៥៧៩ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ចំពោះ លោក **Yoshio TAJIRI** ៥១៧៤

២៤-០៥-២០១៨ -ព្រះរាជក្រឹត្យ នស/រកត/០៥១៨/៥៨០ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្តម **ឆិត្យ ពៅ** និងលោក **សេង វ៉ាន្នី** ៥១៧៥


## II~រាជរដ្ឋាភិបាល

### អនុក្រឹត្យ


២៤-០៥-២០១៨ -អនុក្រឹត្យលេខ ៦៥ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ៥១៧៦

២៤-០៥-២០១៨ -អនុក្រឹត្យលេខ ៦៦ អនក្រ.បក ស្តីពី ការបង្កើតក្រុមស្រាវជ្រាវ វិភាគ និងព្យាករណ៍ ៥១៧៨

២៥-០៥-២០១៨ -អនុក្រឹត្យលេខ ៦៧ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ៥១៨២

០៤-០៦-២០១៨ -អនុក្រឹត្យលេខ ៦៨ អនក្រ.បក ស្តីពី ការធ្វើអនុបយោគ ៥១៨៤

២៥-០៥-២០១៨ -អនុក្រឹត្យលេខ ៥១០ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិកម្ពុជា ៥១៨៦

២៥-០៥-២០១៨ -អនុក្រឹត្យលេខ ៥១១ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិកម្ពុជា ៥១៨៨

២៥-០៥-២០១៨ -អនុក្រឹត្យលេខ ៥១២ អនក្រ.តត ស្តីពី ការផ្ទេរក្របខ័ណ្ឌ នាយទាហាន ៥១៩០

២៥-០៥-២០១៨ -អនុក្រឹត្យលេខ ៥១៣ អនក្រ.តត ស្តីពី ការផ្ទេរ និងតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិកម្ពុជា ៥១៩១

២៥-០៥-២០១៨ -អនុក្រឹត្យលេខ ៥១៦ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៥១៩២

## ២-សេចក្តីសម្រេច

១៤-០៥-២០១៨ -សេចក្តីសម្រេចលេខ ២៨ សសរ ស្តីពី ការកែសម្រួលសមាសភាពគណៈកម្មការបង្ក្រាបបទល្មើសនានា និងត្រួតពិនិត្យការពារការធ្វើនេសាទក្នុងដែនសមុទ្រខេត្តកោះកុង និងតាមបណ្តោយព្រំដែនសមុទ្រកម្ពុជា-ថៃ ៥១៩៣

## III-ការងារបណ្តាក្រសួង

## ១-ទីស្តីការគណៈរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

១២-០៣-២០១៨ -ប្រកាសអន្តរក្រសួងលេខ ២៦១ សហវ.ប្រក ស្តីពី ការបង្កើតរង្វាន់ទេយ្យករបុរេប្រទានសម្រាប់ ឆ្នាំ ២០១៨ នៅក្រសួងព័ត៌មាន ៥១៩៥

១២-០៣-២០១៨ -ប្រកាសលេខ ២៦២ សហវ.ប្រក ស្តីពី ការតែងតាំងគណនេយ្យករប្រចាំនៅវិទ្យាស្ថានជាតិសុខភាពសាធារណៈ នៃក្រសួងសុខាភិបាល ៥២០២

១២-០៣-២០១៨ -ប្រកាសអន្តរក្រសួងលេខ ២៦៣ សហវ.ប្រក ស្តីពី ការបង្កើតរង្វាន់ទេយ្យបុរេប្រទាន សម្រាប់ឆ្នាំ ២០១៨ របស់អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នៃក្រសួងបរិស្ថាន ៥២០៥

១២-០៣-២០១៨ -ប្រកាសអន្តរក្រសួងលេខ ២៦៨ សហវ.ប្រក ស្តីពី ការបង្កើតរង្វាន់ទេយ្យបុរេប្រទាន សម្រាប់ឆ្នាំ ២០១៨ របស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា (ក្រសួងធនធានទឹក និងឧតុនិយម) ៥២១១

១២-០៣-២០១៨ -ប្រកាសអន្តរក្រសួងលេខ ២៦៩ សហវ.ប្រក ស្តីពី ការតែងតាំងភ្នាក់ងារបើកផ្តល់ របស់ក្រសួងមហាផ្ទៃ ផ្នែករដ្ឋបាលទូទៅ ៥២១៤

១២-០៣-២០១៨ -ប្រកាសអន្តរក្រសួងលេខ ២៧០ សហវ.ប្រក ស្តីពី ការបង្កើតរជ្ជទេយ្យបុរេប្រទាន សម្រាប់ ឆ្នាំ ២០១៨ របស់វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា នៃក្រសួងអប់រំ យុវជន និងកីឡា ៥២១៧

១២-០៣-២០១៨ -ប្រកាសអន្តរក្រសួងលេខ ២៧១ សហវ.ប្រក ស្តីពី ការបង្កើតរជ្ជទេយ្យបុរេប្រទាន សម្រាប់ ឆ្នាំ ២០១៨ របស់អគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន នៃក្រសួងបរិស្ថាន ៥២២២

១២-០៣-២០១៨ -ប្រកាសអន្តរក្រសួងលេខ ២៧៣ សហវ.ប្រក ស្តីពី ការបង្កើតរជ្ជទេយ្យបុរេប្រទាន សម្រាប់ ឆ្នាំ ២០១៨ របស់អធិការដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នៃក្រសួងអប់រំ យុវជន និងកីឡា ៥២២៧

**២_ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និង សិប្បកម្ម**

១៨-០១-២០១៨ -ប្រកាសលេខ ០២៤ ឧស.កឧ.ប្រក ០១ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ស្វៃល ហ្គាម៉ិន (ខេមបូឌា) ឯ.ក បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ៥២៣២

២២-០១-២០១៨ -ប្រកាសលេខ ០២៨ ឧស.កឧ.ប្រក ០១ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន វ៉ាន ជៀ ហាវ នីតធីង ឯ.ក បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ៥២៣៥

៣០-០១-២០១៨ -ប្រកាសលេខ ០៣៧ ឧស.កឧ.ប្រក ០១ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន អិលប៊ី វូដ (ខេមបូឌា) ឯ.ក បង្កើតរោងចក្រ ផលិតក្តារប៉ាកេ ក្តារបន្ទះ និងគ្រឿងសង្ហារឹម ៥២៣៨

# ព្រះរាជក្រឹត្យ

នស/រកត/០៥១៨/៤៩០

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣១៥/០០២ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៥/៣២៧ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៥ ស្តីពីការតែងតាំងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦១៥/៦៤៨ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្រមខ័ណ្ឌមន្ត្រីរាជការ នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ឯកឧត្តមប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

## ត្រាស់បង្គាប់

**មាត្រា១** : តម្លើងថ្នាក់ប្រចាំឆ្នាំ ដល់អ្នករាជការ គ.ជ.ប ចំនួន **១២ រូប** នៃក្របខ័ណ្ឌមន្ត្រីបោះឆ្នោតជាន់ខ្ពស់នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចាប់ពី ថ្ងៃទី១៣ ខែមេសា ឆ្នាំ២០១៨ ៖

| | | |
|---|---|---|
| ១- ឯកឧត្តម **សោម សូរីដា** | ពី ឧត្តមមន្ត្រី ថ្នាក់លេខ ២ | មក ឧត្តមមន្ត្រី ថ្នាក់លេខ ១ |
| ២- ឯកឧត្តម **កែវ ផល្លា** | ពី ឧត្តមមន្ត្រី ថ្នាក់លេខ ២ | មក ឧត្តមមន្ត្រី ថ្នាក់លេខ ១ |
| ៣- ឯកឧត្តម **ឆាយ សុផាន់ណា** | ពី ឧត្តមមន្ត្រី ថ្នាក់លេខ ៤ | មក ឧត្តមមន្ត្រី ថ្នាក់លេខ ៣ |
| ៤- ឯកឧត្តម **ហ៊ី រ៉ុង** | ពី ឧត្តមមន្ត្រី ថ្នាក់លេខ ៥ | មក ឧត្តមមន្ត្រី ថ្នាក់លេខ ៤ |
| ៥- ឯកឧត្តម **សយ សាខន** | ពី ឧត្តមមន្ត្រី ថ្នាក់លេខ ៥ | មក ឧត្តមមន្ត្រី ថ្នាក់លេខ ៤ |
| ៦- ឯកឧត្តម **ម៉ុក ដារ៉ា** | ពី ឧត្តមមន្ត្រី ថ្នាក់លេខ ៦ | មក ឧត្តមមន្ត្រី ថ្នាក់លេខ ៥ |
| ៧- ឯកឧត្តម **ខន កែវមនោ** | ពី ឧត្តមមន្ត្រី ថ្នាក់លេខ ៦ | មក ឧត្តមមន្ត្រី ថ្នាក់លេខ ៥ |
| ៨- ឯកឧត្តម **តុប ឫទ្ធី** | ពី ឧត្តមមន្ត្រី ថ្នាក់លេខ ៦ | មក ឧត្តមមន្ត្រី ថ្នាក់លេខ ៥ |
| ៩- ឯកឧត្តម **ទឡ្យ ចំរើន** | ពី ឧត្តមមន្ត្រី ថ្នាក់លេខ ៦ | មក ឧត្តមមន្ត្រី ថ្នាក់លេខ ៥ |
| ១០- ឯកឧត្តម **គង់ សំអាត** | ពី ឧត្តមមន្ត្រី ថ្នាក់លេខ ៦ | មក ឧត្តមមន្ត្រី ថ្នាក់លេខ ៥ |

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

១១- លោកជំទាវ **ប៊ុន សុគី** ពី ឧត្តមមន្ត្រី ថ្នាក់លេខ ៦ មក ឧត្តមមន្ត្រី ថ្នាក់លេខ ៥

១២- ឯកឧត្តម **ជិញ សំគួ** ពី ឧត្តមមន្ត្រី ថ្នាក់លេខ ៦ មក ឧត្តមមន្ត្រី ថ្នាក់លេខ ៥

**មាត្រា២** : ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចាប់ស. ១៤០៥.៤៩៦

លេខ: ៦០៣ ស.ណ

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ០៨ ខែឧសភា ឆ្នាំ២០១៨*

**សំណៅចែលមានតម្លៃជាការចែកផ្សាយ**
ថ្ងៃអង្គារ ១៥កើត ខែជេស្ឋ ឆ្នាំចសំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែឧសភា ឆ្នាំ២០១៨
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៥១៨/៥៥៧

## ស្តីពី
## ការរៀបចំនិងការប្រព្រឹត្តទៅ
## នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៣/០១២ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា២៨ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១១២/០០១ ចុះថ្ងៃទី២ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០៩/៦០៨ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ព្រះរាជក្រឹត្យ — ត្រាស់បង្គាប់

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ត្រូវបានបង្កើតអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដែលសរសេរជាអក្សរកាត់ថា **អ.ជ.ប.គ.ញ.** ជាស្ថាប័នអនុវត្តគោលនយោបាយនិងជាសេនាធិការជូនរាជរដ្ឋាភិបាលក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន។

## ជំពូកទី២
## សមាសភាពរបស់អ.ជ.ប.គ.ញ.

**មាត្រា២ .-**

**អ.ជ.ប.គ.ញ.** មានសមាសភាពដូចខាងក្រោម៖

- ឧបនាយករដ្ឋមន្ត្រី១រូប — ប្រធាន
- រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ — អនុប្រធាន
- រដ្ឋមន្ត្រីក្រសួងការពារជាតិ — អនុប្រធាន
- រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ — អនុប្រធាន
- រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា — អនុប្រធាន
- រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា — អនុប្រធាន
- រដ្ឋមន្ត្រីក្រសួងសុខាភិបាល — អនុប្រធាន
- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី — សមាជិក
- រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច — សមាជិក
- រដ្ឋមន្ត្រីក្រសួងផែនការ — សមាជិក
- រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ — សមាជិក
- រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ — សមាជិក
- រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ — សមាជិក
- រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន — សមាជិក
- រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មនិងសិប្បកម្ម — សមាជិក
- រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា — សមាជិក
- រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ — សមាជិក
- រដ្ឋមន្ត្រីក្រសួងព័ត៌មាន — សមាជិក
- រដ្ឋមន្ត្រីក្រសួងកិច្ចការនារី — សមាជិក
- រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម — សមាជិក
- រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ — សមាជិក
- រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ — សមាជិក
- រដ្ឋមន្ត្រីក្រសួងទេសចរណ៍ — សមាជិក
- រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ — សមាជិក
- រដ្ឋមន្ត្រីក្រសួងបរិស្ថាន — សមាជិក
- រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ — សមាជិក
- ទេសាភិបាលធនាគារជាតិនៃកម្ពុជា — សមាជិក

- រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល សមាជិក
- អគ្គលេខាធិការនៃ **អ.ជ.ប.គ.ញ** សមាជិកនិងជាលេខាធិការ។

ក្នុងករណីចាំបាច់ ប្រធាន**អ.ជ.ប.គ.ញ** អាចស្នើសុំតែងតាំងឥស្សរជន១រូប ជាអនុប្រធាន មានឋានៈស្មើរដ្ឋមន្ត្រី។

## ជំពូកទី៣
## តួនាទីនិងភារកិច្ចរបស់អ.ជ.ប.គ.ញ.

**មាត្រា៣ .-**

**អ.ជ.ប.គ.ញ.** មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- អនុវត្តបទប្បញ្ញត្តិអនុសញ្ញាទោលស្តីពីគ្រឿងញៀនឆ្នាំ១៩៦១ ដែលបានធ្វើវិសោធនកម្មដោយពិធីសារឆ្នាំ១៩៧២ អនុសញ្ញាស្តីពីសារធាតុដែលធ្វើឱ្យប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ ឆ្នាំ១៩៧១ និងអនុសញ្ញារបស់អង្គការសហប្រជាជាតិប្រឆាំងនឹងការចរាចរខុសច្បាប់នូវគ្រឿងញៀននិងសារធាតុដែលធ្វើឱ្យប៉ះពាល់សរសៃប្រសាទឆ្នាំ១៩៨៨និងលិខិតុបករណ៍អន្តរជាតិនានាដែលទាក់ទងនឹងគ្រឿងញៀនដែលព្រះរាជាណាចក្រកម្ពុជាជាសមាជិក
- រៀបចំគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាព ដើម្បីទប់ស្កាត់ការដាំដុះ ការផលិត ការចរាចរ ការជួញដូរគ្រឿងញៀន និងសារធាតុគីមីផ្សំគ្រឿងញៀន
- រៀបចំគោលនយោបាយ យុទ្ធសាស្ត្រ ផែនការសកម្មភាព និងជំរុញការងារផ្សព្វផ្សាយអប់រំ ដើម្បីលើកកម្ពស់ឱ្យមានការយល់ដឹងពីបញ្ហានិងផលប៉ះពាល់នៃគ្រឿងញៀនដល់សាធារណជន ដើម្បីកាត់បន្ថយ និងឈានទៅលុបបំបាត់ទាំងការប្រើប្រាស់និងការជួញដូរគ្រឿងញៀន
- រៀបចំគោលនយោបាយ យុទ្ធសាស្ត្រ ផែនការសកម្មភាព និងជំរុញការងារកាត់បន្ថយគ្រោះថ្នាក់ ការព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន សំដៅបង្ការនិងទប់ស្កាត់រាល់គ្រោះថ្នាក់ផ្នែកសុខភាព ក្នុងចំណោមអ្នកប្រើប្រាស់គ្រឿងញៀននិងពីអ្នកប្រើប្រាស់គ្រឿងញៀនទៅអ្នកដទៃនៅក្នុងគ្រួសារនិងក្នុងសហគមន៍
- រៀបចំតាក់តែងអត្ថបទច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីការត្រួតពិនិត្យគ្រឿងញៀនដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ
- បង្កើតនិងគ្រប់គ្រងមជ្ឈមណ្ឌលអប់រំ ព្យាបាល និងស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ និងសមាហរណកម្មអ្នកជាសះស្បើយពីគ្រឿងញៀនចូលក្នុងសហគមន៍និងគ្រួសារវិញ
- ដឹកនាំ ជំរុញ និងសម្របសម្រួលគ្រប់យន្តការដើម្បីធានាការអនុវត្តច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងគ្រឿងញៀនឱ្យមានប្រសិទ្ធភាព
- ដឹកនាំ សម្របសម្រួល និងត្រួតពិនិត្យការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន
- រៀបចំ ដឹកនាំ និងសម្របសម្រួលយន្តការអន្តរក្រសួង ស្ថាប័ន ក្នុងការតាមដាន ការប្រមូល ការគ្រប់គ្រង និងការចាត់ចែងរាល់មុខសញ្ញា ដែលជាប្រភពនៃមូលនិធិជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន ដើម្បីធានាថាការប្រមូល ការគ្រប់គ្រង និងការចាត់ចែងមូលនិធិនេះ ប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព
- លើកទឹកចិត្តដល់អ្នកផ្តួចផ្តើមគំនិតក្នុងការប្រយុទ្ធប្រឆាំងនឹងជំនួញគ្រឿងញៀន សារធាតុសម្រាប់ផ្សំគ្រឿងញៀន និងការសម្អាតប្រាក់បានមកពីជំនួញគ្រឿងញៀនខុសច្បាប់

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

- ចូលរួមនិងអនុវត្តនីតិវិធីនានាដូចមានចែងនៅក្នុងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងក្រមនីតិវិធីព្រហ្មទណ្ឌទាក់ទងនឹងបទល្មើសគ្រឿងញៀន
- សហការជាមួយសប្បុរសជនជាតិ អន្តរជាតិ អង្គការដៃគូអភិវឌ្ឍនានា និងសហគមន៍អន្តរជាតិ ដើម្បីស្វែងរកថវិកា មូលនិធិ ឬការគាំទ្រដទៃទៀត សម្រាប់សកម្មភាពប្រយុទ្ធប្រឆាំងគ្រឿងញៀន
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន។

**មាត្រា៤ .-**

ក្រសួង ស្ថាប័ន ដែលជាសមាជិករបស់ **អ.ជ.ប.គ.ញ.** ត្រូវមានយន្តការនិងថវិកាដែលគាំទ្រដល់សកម្មភាពប្រយុទ្ធប្រឆាំងគ្រឿងញៀន ដើម្បីអនុវត្តតួនាទីនិងភារកិច្ចពាក់ព័ន្ធនឹងការងារប្រយុទ្ធប្រឆាំងគ្រឿងញៀនក្នុងដែនសមត្ថកិច្ចនិងជំនាញរបស់ខ្លួន។

## ជំពូកទី៤
## ការប្រព្រឹត្តទៅរបស់អ.ជ.ប.គ.ញ.

**មាត្រា៥ .-**

**អ.ជ.ប.គ.ញ.** ត្រូវធ្វើការប្រជុំយ៉ាងតិច០២(ពីរ)ដងក្នុងមួយឆ្នាំតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីដែលប្រធានមានធុរៈ ប្រធានអាចប្រគល់ភារកិច្ចជូនអនុប្រធានណាម្នាក់ដើម្បីដឹកនាំកិច្ចប្រជុំជំនួស។

គ្រប់ពេលប្រជុំរបស់**អ.ជ.ប.គ.ញ.** ប្រសិនបើសមាជិកណាម្នាក់មានធុរៈមិនអាចចូលរួមប្រជុំបាន សមាជិកនោះត្រូវចាត់តាំងតំណាងមួយរូបដែលមានសិទ្ធិសម្រេចមកចូលរួមប្រជុំជំនួស។

**មាត្រា៦ .-**

**អ.ជ.ប.គ.ញ.** អាចអញ្ជើញតំណាងក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធ មន្ត្រីជំនាញ ដៃគូអភិវឌ្ឍពាក់ព័ន្ធនានា ឬផ្នែកឯកជន ឱ្យចូលរួមប្រជុំពិគ្រោះយោបល់និងសិក្សាស្រាវជ្រាវលើរាល់បញ្ហាទាំងឡាយដែលពាក់ព័ន្ធនឹងក្របខ័ណ្ឌការងាររបស់ខ្លួន។

**មាត្រា៧ .-**

**អ.ជ.ប.គ.ញ.** អាចបង្កើតគណៈកម្មាធិការជំនាញមួយចំនួនតាមការចាំបាច់ ដើម្បីបំពេញការងាររបស់ខ្លួនឱ្យមានប្រសិទ្ធភាព។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជំនាញនីមួយៗ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់ប្រធាន **អ.ជ.ប.គ.ញ.**។

**មាត្រា៨ .-**

**អ.ជ.ប.គ.ញ.** មានគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀននៅតាមរាជធានី ខេត្ត ជាសេនាធិការ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិកាត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រា៩ .-**

**អ.ជ.ប.គ.ញ.** មានទីប្រឹក្សានិងជំនួយការតាមការចាំបាច់។

**មាត្រា១០ .-**

**អ.ជ.ប.គ.ញ.** មានរូបសញ្ញានិងត្រាសម្រាប់ប្រើជាផ្លូវការ។

រូបសញ្ញានិងត្រារបស់ **អ.ជ.ប.គ.ញ.** ជាឧបសម្ព័ន្ធនៃព្រះរាជក្រឹត្យនេះ។

## ជំពូកទី៥
## អគ្គលេខាធិការដ្ឋាននៃអ.ជ.ប.គ.ញ.

**មាត្រា១១ .-**

**អ.ជ.ប.គ.ញ.** មានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការ ដែលមានទីតាំងនៅក្រសួងមហាផ្ទៃ។

អគ្គលេខាធិការដ្ឋាននៃ **អ.ជ.ប.គ.ញ.** ត្រូវស្ថិតនៅក្នុងរចនាសម្ព័ន្ធនៃក្រសួងមហាផ្ទៃ។

អគ្គលេខាធិការដ្ឋាននៃ **អ.ជ.ប.គ.ញ.** ស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់ប្រធាន **អ.ជ.ប.គ.ញ.**។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃ **អ.ជ.ប.គ.ញ.** ត្រូវកំណត់ដោយអនុក្រឹត្យ។

អគ្គលេខាធិការដ្ឋាននេះ មានមន្ត្រីបម្រើការងារមកពីក្របខណ្ឌក្រសួងមហាផ្ទៃ។ ក្នុងករណីចាំបាច់ ប្រធាន **អ.ជ.ប.គ.ញ.** មានសិទ្ធិស្នើសុំមន្ត្រីក្របខណ្ឌពីស្ថាប័ននានាមកបម្រើការងារនៅអគ្គលេខាធិការដ្ឋាន នៃ **អ.ជ.ប.គ.ញ.** ឬមានសិទ្ធិស្នើសុំមន្ត្រីតាមរយៈការជ្រើសរើសក្របខណ្ឌមន្ត្រីថ្មីរបស់ក្រសួងមហាផ្ទៃ ឬមានសិទ្ធិជ្រើសរើសមន្ត្រីជាប់កិច្ចសន្យាមកបម្រើការងារ។

អគ្គលេខាធិការដ្ឋាននៃ **អ.ជ.ប.គ.ញ.** ត្រូវដឹកនាំដោយអគ្គលេខាធិការមួយរូបនិងមានអគ្គលេខាធិការរងមួយចំនួនជាជំនួយការតាមការចាំបាច់ស្របតាមបទប្បញ្ញត្តិជាធរមាន។

អគ្គលេខាធិការនិងអគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋាននៃ**អ.ជ.ប.គ.ញ.** ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ឬអនុក្រឹត្យ តាមសំណើរបស់ប្រធាន **អ.ជ.ប.គ.ញ.**។

ប្រធាន **អ.ជ.ប.គ.ញ.** មានសិទ្ធិស្នើសុំតែងតាំង ឬស្នើសុំដំឡើងឋានន្តរស័ក្តិ ឬដាក់ពិន័យមន្ត្រីរាជការក្រោមឱវាទអគ្គលេខាធិការដ្ឋាននៃ **អ.ជ.ប.គ.ញ.**។

## ជំពូកទី៦
## ប្រភពធនធាននិងមូលនិធិរបស់អ.ជ.ប.គ.ញ.

**មាត្រា១២ .-**

**អ.ជ.ប.គ.ញ.** មានថវិកាដោយឡែករបស់ខ្លួន ដែលជាឧបសម្ព័ន្ធនៃថវិការបស់ក្រសួងមហាផ្ទៃ។

**អ.ជ.ប.គ.ញ.** មានសិទ្ធិទទួលនិងចាត់ចែង ប្រើតាមនីតិវិធីច្បាប់ជាធរមាននូវមូលនិធិដែលបានមកពីប្រភពផ្សេងៗសម្រាប់ដំណើរការការងាររបស់ខ្លួន។

**មាត្រា១៣ .-**

ប្រធាន **អ.ជ.ប.គ.ញ.** ត្រូវបានទទួលការតែងតាំងឱ្យអនុវត្តសិទ្ធិអាណាប័កជំនួស «អាណាប័កផ្ទេរសិទ្ធិ» តាមការសម្រេចចិត្តរបស់អាណាប័កដើមខ្សែ។

ប្រធាន **អ.ជ.ប.គ.ញ.** មានសិទ្ធិសម្រេចលើការប្រើប្រាស់ថវិកាសម្រាប់អគ្គលេខាធិការដ្ឋាននៃ **អ.ជ.ប.គ.ញ.** និងមានសិទ្ធិចាត់ចែងមូលនិធិជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន។

**មាត្រា១៤ .-**

គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត មានថវិកាសម្រាប់អនុវត្តការងាររបស់ខ្លួនក្នុងគម្រោងកញ្ចប់ថវិការបស់រាជធានី ខេត្ត នីមួយៗ។

## ជំពូកទី៧
## អន្តរប្បញ្ញត្តិ

[illegible]នុគតិយុត្តក្រោមព្រះរាជក្រឹត្យពាក់ព័ន្ធនឹងព្រះរាជក្រឹត្យលេខ នស/រកត/០៥០៩/៦០៨ ចុះថ្ងៃទី៣០

ខែឧសភា ឆ្នាំ២០០៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ត្រូវមានអានុភាព អនុវត្តបន្តរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស។

## ជំពូកទី៨
## អវសានប្បញ្ញត្តិ

**មាត្រា១៦ .-**

ព្រះរាជក្រឹត្យលេខ នស/រកត/០៥០៩/៦០៨ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៧ .-**

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

នស/រកត/០៥១៨/៥៦៣

ថ្ងៃព្រហ ៩កើត ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ២០១៨

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
**ឧបនាយករដ្ឋមន្ត្រី**
**ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន**
**ហត្ថលេខា**
**កែ គឹមយ៉ាន**

លេខៈ៥៧៥ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
ថ្ងៃសុក្រ ១១កើត ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែ ឧសភា ឆ្នាំ២០១៨
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៥១៨/៥៥៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** បញ្ចប់មុខតំណែងឯកឧត្តម **ហូ ចំរើន** ពីទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ **រដ្ឋលេខាធិការ** ។

**មាត្រា ២ :** លុបឈ្មោះ ឯកឧត្តម ឧត្តមសេនីយ៍ឯក **ហូ ចំរើន** អត្តលេខ ០០២៩៥៨ នាយទាហានថ្នាក់ឧត្តមសេនីយ៍ នៃកងយោធពលខេមរភូមិន្ទ ចេញពីក្របខ័ណ្ឌនៃកងយោធពលខេមរភូមិន្ទ ។

**មាត្រា ៣ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៧៣៨.១៩០៥.៥៦៤

លេខៈ ៥៩០ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
ថ្ងៃសុក្រ ១១កើត ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែឧសភា ឆ្នាំ២០១៨
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ២៣ ខែឧសភា ឆ្នាំ២០១៨*

# ព្រះរាជក្រឹត្យ

នស/រកត/០៥១៨/៥៥៩

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

**ប្រោសព្រះរាជទាន**

**នូវ**

**គ្រឿងឥស្សរិយយស ជាតូបការ**

| | | | |
|---|---|---|---|
| ១- | ឧត្តមសេនីយ៍ឯក | **អន មុន្នី** | អត្តលេខ ០០០២៦៩ |
| ២- | ឧត្តមសេនីយ៍ឯក | **អ៊ុក សារ៉ន** | អត្តលេខ ០០០៦៩៥ |
| ៣- | ឧត្តមសេនីយ៍ឯក | **ទឹម សិទ្ធា** | អត្តលេខ ០០០៦៣១ |
| ៤- | ឧត្តមសេនីយ៍ឯក | **គឹម រស្មី** | អត្តលេខ ០៣៦៧១៨ |

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចរល.១៥០៥.៥៦៥

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ២៣ ខែឧសភា ឆ្នាំ២០១៨*

លេខៈ ៥៩១ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
ថ្ងៃសុក្រ ១១កើត ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែឧសភា ឆ្នាំ២០១៨
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

នស/រកត/០៥១៨/៥៦០

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

**ប្រោសព្រះរាជទាន**

ជូន

**ក- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ :**

១- ឯកឧត្តម **ឆេព កល្យាណ**

២- ឯកឧត្តម **ហ៊ឹម ម៉ាន់ឌី**

**ខ- គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ :**

- លោកជំទាវ **ហេ សៀកឡេង**

**គ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា :**

-ឯកឧត្តម **អ៊ុំ សង់អុន**

**ឃ- គ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេនា :**

១- **ស្ថានទូតជប៉ុន** Embassy of Japan

២- **ស្ថានទូតសហរដ្ឋអាមេរិក** Embassy of the United States of America

៣- **ស្ថានទូតអូស្ត្រាលី** Embassy of Australia

៤- **ស្ថានទូតចក្រភពអង់គ្លេស** Embassy of United Kingdom

៥- **ស្ថានទូតអាល្លឺម៉ង់** Embassy of Germany

៦- **ស្ថានទូតស្វ៊ីស** Embassy of Switzerland

៧- **ស្ថានទូតកាណាដា** Embassy of Canada

៨- **អង្គការ** UNDP

**ព្រះហស្តលេខា និងព្រះរាជលញ្ចករ**
**នរោត្តម សីហមុនី**

ចារ. ១៩០៥. ៥៦៦

ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ២៣ ខែឧសភា ឆ្នាំ២០១៨

លេខៈ ៥៨២ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
ថ្ងៃសុក្រ ១១កើត ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែឧសភា ឆ្នាំ២០១៨
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊យ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៥១៨/៥៦១

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៦ ស្តីពីការបញ្ចប់មុខងារ និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** បញ្ចប់មុខតំណែងឯកឧត្តម **ជា ធីរៈ** ពី ឯកអគ្គរាជទូតវិសាមញ្ញនិងពេញសមត្ថភាពនៃព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសបែលហ្សិក និង ពី ឯកអគ្គរាជទូតតែងតាំងប្រចាំប្រទេសអូទ្រីស ហូឡង់ លុចហ្សំបួរ និងអមសហភាពអឺរ៉ុបចូលប្រទេសវិញ ដោយត្រូវចប់អាណត្តិបេសកកម្ម ។

**មាត្រា ២:** តែងតាំងមុខតំណែងឯកឧត្តម **ឈុំ ពិសិដ្ឋ** អគ្គនាយកនៃអគ្គនាយកដ្ឋានអឺរ៉ុប អាមេរិក និងអាហ្វ្រិក-មជ្ឈិមបូព៌ានៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ជា **ឯកអគ្គរាជទូត** វិសាមញ្ញ និងពេញសមត្ថភាពនៃព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសបែលហ្សិក និងជាឯកអគ្គរាជទូតតែងតាំងប្រចាំប្រទេសអូទ្រីស ហូឡង់ លុចហ្សំបួរ និងអមសហភាពអឺរ៉ុបដែលមាននិវេសនដ្ឋាន នៅទីក្រុងប្រ៊ុយសែល ប្រទេសបែលហ្សិក ។

**មាត្រា ៣:** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ជ.ភ.ណ. ១៤០៥. ៥៦៧

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ២៣ ខែឧសភា ឆ្នាំ២០១៨*

លេខ: ៥៤៣ ស.ណ
**សំណៅដែលមានគម្លៃជាការចែកផ្សាយ**
ថ្ងៃសុក្រ ១១កើត ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែឧសភា ឆ្នាំ២០១៨
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៥១៨/៥៦២

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៦ ស្តីពីការបញ្ចប់មុខងារ និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** បញ្ចប់មុខតំណែងឯកឧត្តម **ពេជ្រឃុន បញ្ញា** ពីឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជាប្រចាំសាធារណរដ្ឋឥណ្ឌា និងពី ឯកអគ្គរាជទូតតែងតាំងប្រចាំប្រទេស បង់ក្លាដេស ស្រីលង្កា ប៉ាគីស្ថាន និងសាធារណរដ្ឋអ៊ីស្លាមអ៊ីរ៉ង់ **ចូលប្រទេសវិញ** ដោយត្រូវចប់អាណត្តិបេសកកម្ម។

**មាត្រា ២:** តែងតាំងមុខតំណែងឯកឧត្តម **អ៊ុង សារ៉ន** រដ្ឋលេខាធិការ នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជា **ឯកអគ្គរាជទូត** វិសាមញ្ញ និងពេញសមត្ថភាពនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋឥណ្ឌា និងជាឯកអគ្គរាជទូតតែងតាំងប្រចាំប្រទេសបង់ក្លាដេស ស្រីលង្កា ប៉ាគីស្ថាន និងសាធារណរដ្ឋអ៊ីស្លាមអ៊ីរ៉ង់ ដែលមាននិវេសនដ្ឋាននៅទីក្រុងញូវដេលី សាធារណរដ្ឋឥណ្ឌា។

**មាត្រា ៣:** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

ពាន.១៨០៥.៥៦៥

ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ២៣ ខែឧសភា ឆ្នាំ២០១៨

លេខៈ ៥៧៨ ស.ណ

**សំណៅដែលមានអង្គជាការចែកផ្សាយ**

ថ្ងៃសុក្រ ១១កើត ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែឧសភា ឆ្នាំ២០១៨

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៥១៨/៥៦៣

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៦ ស្តីពីការបញ្ចប់មុខងារ និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១:** បញ្ចប់មុខតំណែងលោកជំទាវ **ជា គឹមថា** ពីឯកអគ្គរាជទូតវិសាមញ្ញនិងពេញសមត្ថភាពនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំប្រទេសជប៉ុន ចូលប្រទេសវិញ ដោយត្រូវចប់អាណត្តិបេសកកម្ម។

**មាត្រា២:** តែងតាំងមុខតំណែងឯកឧត្តម **អ៊ឹង ចេនា** អគ្គនាយកនៃអគ្គនាយកដ្ឋានអាស៊ី-ប៉ាស៊ីហ្វិក ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ជា**ឯកអគ្គរាជទូត** វិសាមញ្ញនិងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសជប៉ុន។

**មាត្រា៣:** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចាវសា.១៨០៥.៥៦៩

លេខ:៥៧៨ ស.ណ
**សំណៅចែបមានតម្លៃជាការចែកផ្សាយ**
ថ្ងៃសុក្រ ១០កើត ខែជេស្ឋ ឆ្នាំចសំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែឧសភា ឆ្នាំ២០១៨
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**សយ សុខា**

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ២៣ ខែឧសភា ឆ្នាំ២០១៨*

# ព្រះរាជក្រឹត្យ

នស/រកត/០៥១៨/៥៦៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៦ ស្តីពីការបញ្ចប់មុខងារ និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១**: បញ្ចប់មុខតំណែងលោកជំទាវ **ឡុត បញ្ញា** ពីឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពនៃព្រះរាជាណាចក្រកម្ពុជាប្រចាំសាធារណរដ្ឋហ្វីលីពីនចូលប្រទេសវិញ ដោយត្រូវចប់អាណត្តិបេសកកម្ម។

**មាត្រា២**: តែងតាំងមុខតំណែងឯកឧត្តម **ឡេង ចាន់ធីរៈ** អគ្គាធិការនៃក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ជា**ឯកអគ្គរាជទូត** វិសាមញ្ញនិងពេញសមត្ថភាពនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋហ្វីលីពីន។

**មាត្រា៣**: សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ២៣ ខែឧសភា ឆ្នាំ២០១៨

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចាភ.១៨០៥-៥៧០

លេខ: ៥៧៧ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
ថ្ងៃសុក្រ ១០កើត ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែឧសភា ឆ្នាំ២០១៨
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៥១៨/៥៦៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៦ ស្តីពីការបញ្ចប់មុខងារ និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា១:** បញ្ចប់មុខតំណែងឯកឧត្តម **ទុយ រី** ពីឯកអគ្គរាជទូតតំណាងអចិន្ត្រៃយ៍ ប្រចាំអង្គការសហប្រជាជាតិ និងប្រទេសកាណាដា ចូលប្រទេសវិញ ដោយត្រូវចប់អាណត្តិបេសកកម្ម ។

**មាត្រា២:** តែងតាំងមុខតំណែងឯកឧត្តម **កែ សុវណ្ណ** តំណាងអចិន្ត្រៃយ៍រងនៃស្ថានបេសកម្មអចិន្ត្រៃយ៍នៃព្រះរាជាណាចក្រកម្ពុជាប្រចាំអង្គការសហប្រជាជាតិ និងប្រទេសកាណាដា ជា **ឯកអគ្គរាជទូត** តំណាងអចិន្ត្រៃយ៍ប្រចាំអង្គការសហប្រជាជាតិ និងប្រទេសកាណាដា ដែលមាននិវេសនដ្ឋាននៅទីក្រុងញូវយ៉ក សហរដ្ឋអាមេរិក ។

**មាត្រា៣:** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣ទស.៧៩០៥.៥០៧១

លេខៈ ៥៧៦ ស.ណ

**សំណៅចែបមានតម្លៃជាការចែកផ្សាយ**

ថ្ងៃសុក្រ ១១កើត ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១៨*

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែឧសភា ឆ្នាំ២០១៨

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៥១៨/៥៦៦

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៦ ស្តីពីការបញ្ចប់មុខងារ និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១**: បញ្ចប់មុខតំណែងឯកឧត្តម **ជុំ ប៊ុនរ៉ុង** ពីឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពនៃព្រះរាជាណាចក្រកម្ពុជាប្រចាំសហរដ្ឋអាមេរិក និង ពីឯកអគ្គរាជទូតតែងតាំង ប្រចាំរដ្ឋម៉ិកស៊ិកូ ចូលប្រទេសវិញ ដោយត្រូវចប់អាណត្តិបេសកកម្ម។

**មាត្រា២**: តែងតាំងមុខតំណែងឯកឧត្តម **ជុំ សុន្ទរី** អនុរដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជា **ឯកអគ្គរាជទូត** វិសាមញ្ញ និងពេញសមត្ថភាពនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសហរដ្ឋអាមេរិក និងជាឯកអគ្គរាជទូតតែងតាំងប្រចាំរដ្ឋម៉ិកស៊ិកូ ដែលមាននិវេសនដ្ឋាន នៅទីក្រុងវ៉ាស៊ីងតោន សហរដ្ឋអាមេរិក។

**មាត្រា៣**: សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៧ខល.១៩០៥.៥៧៤

លេខៈ ៥៧៤ ស.ណ

**សំណៅចម្លងដែលមានតម្លៃជាការចែកផ្សាយ**

ថ្ងៃសុក្រ ១១កើត ១០ជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១៨

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែឧសភា ឆ្នាំ២០១៨

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៥១៨/៥៦៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៦ ស្តីពីការបញ្ចប់មុខងារ និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា១:** បញ្ចប់មុខតំណែងឯកឧត្តម **កេត សោផាន់** ពីឯកអគ្គរាជទូត ប្រតិភូអចិន្ត្រៃយ៍ ប្រចាំអង្គការយូណេស្កូ និង ពីនាយកផ្ទះខ្មែរ(Maison du Cambodge) នៅមជ្ឈមណ្ឌលសាកលវិទ្យាល័យ នៅទីក្រុងប៉ារីស ចូលប្រទេសវិញ ដោយត្រូវចប់អាណត្តិបេសកកម្ម។

- ផលិតព័ត៌មានប្រចាំថ្ងៃ ព័ត៌មានបច្ចុប្បន្នភាព អត្ថបទវិភាគ ឯកសារស្រាវជ្រាវយុទ្ធសាស្ត្រ និងរៀបចំជំនួយស្មារតី ជូនសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

- សម្របសម្រួលការងារជាមួយគ្រប់អង្គភាពរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និង គ្រប់ក្រសួង/ស្ថាប័នរដ្ឋ ស្ថាប័នឯកជន ធនាគារខួរក្បាល គ្រឹះស្ថានឧត្តមសិក្សា វិទ្យាស្ថានស្រាវជ្រាវ រួមទាំងស្ថាប័នបរទេសផងដែរ ក្នុងបុព្វហេតុស្រាវជ្រាវ និទស្សន៍ វិភាគ និងព្យាករណ៍ឲ្យមានប្រសិទ្ធភាព។
- បំពេញការងារផ្សេងៗទៀត តាមអនុសាសន៍ និងការណែនាំរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

**មាត្រា៤.-**

ក្រុមស្រាវជ្រាវ វិភាគ និងព្យាករណ៍ ដឹកនាំដោយអគ្គនាយកមួយរូប និងអមដោយអគ្គនាយករងមួយចំនួន ដែលមាននាយកដ្ឋានចំណុះចំនួន ៤ (បួន)។ ក្រុមនេះ អាចមានទីប្រឹក្សា និងជំនួយការ ព្រមទាំងអ្នកស្រាវជ្រាវ ដែលមាន ៣ (បី) កម្រិត គឺ អ្នកស្រាវជ្រាវជាន់ខ្ពស់ អ្នកស្រាវជ្រាវ និងអ្នកស្រាវជ្រាវហ្វឹកហាត់ សម្រាប់ជួយដល់ដំណើរការការងារទៅតាមការចាំបាច់។

**មាត្រា៥.-**

ក្រុមស្រាវជ្រាវ វិភាគ និងព្យាករណ៍ មាននាយកដ្ឋានក្រោមឱវាទចំនួន ៤ (បួន) ដូចខាងក្រោម៖

- **នាយកដ្ឋានវិភាគ និងព្យាករណ៍នយោបាយតំបន់ និងពិភពលោក៖** បំពេញមុខងារស្រាវជ្រាវ តាមដាន ស្វែងយល់ ចងក្រង និទស្សន៍ វិភាគ វាយតម្លៃ និងព្យាករណ៍អំពីការវិវត្តនៃស្ថានការណ៍ និងនិន្នាការនយោបាយនៅក្នុងតំបន់ និងពិភពលោក។
- **នាយកដ្ឋានវិភាគ និងព្យាករណ៍នយោបាយជាតិ៖** បំពេញមុខងារស្រាវជ្រាវ តាមដាន ស្វែងយល់ ចងក្រង និទស្សន៍ វិភាគ វាយតម្លៃ និងព្យាករណ៍អំពីការវិវត្តនៃនយោបាយជាតិ សេដ្ឋកិច្ច សង្គម-វប្បធម៌ និងសាសនា។
- **នាយកដ្ឋានវិភាគ និងព្យាករណ៍សេដ្ឋកិច្ច និងបញ្ហាសកល៖** បំពេញមុខងារស្រាវជ្រាវ តាមដាន ស្វែង-យល់ ចងក្រង និទស្សន៍ វិភាគ វាយតម្លៃ និងព្យាករណ៍អំពីការប្រែប្រួលនៃសេដ្ឋកិច្ចនៅក្នុងតំបន់ និងពិភពលោក និងអំពីបញ្ហាប្រឈមសកលនានា។
- **នាយកដ្ឋានទ្រទ្រង់៖** បំពេញមុខងារជានាដល់ដំណើរការទ្រទ្រង់លើកិច្ចការរដ្ឋបាលទូទៅ ហិរញ្ញវត្ថុ គណនេយ្យ បច្ចេកវិទ្យាព័ត៌មាន និងផ្គត់ផ្គង់ ទុកដាក់និងរៀបចំឯកសារ/ទិន្នន័យនានា ហើយនិងសម្របសម្រួលកិច្ចការសាធារណៈជាមួយបណ្ដានាយកដ្ឋាននៃក្រសួងការបរទេស និងសហប្រតិបត្តិ-ការអន្តរជាតិ និងជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីបម្រើឲ្យកិច្ចការស្រាវជ្រាវ វិភាគ និងព្យាករណ៍។

**មាត្រា៦.-**

ការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋានចំណុះរបស់ក្រុមស្រាវជ្រាវ វិភាគ និងព្យាករណ៍ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

**មាត្រា៧.-**

ក្រុមស្រាវជ្រាវ វិភាគ និងព្យាករណ៍ មានកញ្ចប់ថវិកា សម្រាប់ដំណើរការការងារក្នុងថវិការបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

## ជំពូកទី៣
## អន្តរប្បញ្ញត្តិ

**មាត្រា៨.-**

បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**ជំពូកទី៤**

**អវសានប្បញ្ញត្តិ**

**មាត្រា៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ១០ កើត ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**

**ប្រាក់ សុខុន**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៦៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការផ្ទេរឥណទានថវិកា

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៧/០១៩ ចុះថ្ងៃ សៅរ៍ ០៦រោច ខែ មិគសិរ ឆ្នាំ រកា ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី ០៩ ខែ ធ្នូ គ.ស.២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៨
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៣៧ អនក្រ.បក ចុះថ្ងៃ ច័ន្ទ ០៨ កើត ខែ បុស្ស ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១ ត្រូវនឹងថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០១៧ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៨
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១.-**

ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាចំនួន ២០០ ០០០ ០០០ រៀល (ពីររយលានរៀលគត់) ពីជំពូក ៦៩ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែកមកជំពូក ៦១ (សេវាកម្ម) ជូនក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៨។

**មាត្រា២.-**

ការបែងចែកឥណទានថវិកាចំណាយផ្ទេរក្នុងជំពូកនេះតាមគណនីនិងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ផ្ដល់ជូនស្ថានទូតកម្ពុជាប្រចាំប្រទេសជប៉ុន សម្រាប់រៀបចំពិធីជប់លៀងអបអរសាទរខួបលើកទី ៦៥ នៃចំណងមិត្តភាពរវាងកម្ពុជា-ជប៉ុន។

**មាត្រា៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១១ កើត ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែឧសភា ឆ្នាំ ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន

សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច/ឯកឧត្ដម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៦៨ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការធ្វើអនុបយោគ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងនីតិបុគ្គលសាធារណៈ
- លិខិតលេខ ១០២២ សជណ ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- លិខិតលេខ៦៥៤ សជណ ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០០៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- លិខិតលេខ១៤២៩/០០៩ កសក.លស ចុះថ្ងៃទី០៨ខែកុម្ភៈ ឆ្នាំ២០១៨របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

### សម្រេច

**មាត្រា១៖**

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ ៣០៦០,១៧០២ ហិកតា (បីពាន់ហុកសិបហិកតា ដប់ប្រាំពីរអារនិងពីរសង់ទីអារ) ដែលមានទីតាំងស្ថិតនៅឃុំទីពោ ស្រុកសន្ទុក និងឃុំតាំងក្រសៅ ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ របស់ក្រុមហ៊ុន ប៊ី អិន អេ (ខេម) ខប B N A (CAM) CORP បានធ្វើប្លង់បង្ហាញទីតាំងដី ជាកម្មវត្ថុ

នៃការចុះបញ្ជីដីរដ្ឋ ជាគោលដៅសម្បទានដីសេដ្ឋកិច្ច និងទទួលបានឃើញ និងឯកភាព ពីឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៥ និងមានប័ណ្ណសម្គាល់សិទ្ធកាន់កាប់អចលនវត្ថុចំនួន ១៥ប័ណ្ណ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៦ របស់មន្ទីររៀបចំដែនដី នគររូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តកំពង់ធំ ពីទ្រព្យសម្បត្តិសាធារណៈ របស់រដ្ឋមកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ។

**មាត្រា២៖**

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគដូចកំណត់ក្នុងមាត្រា១នៃអនុក្រឹត្យនេះ ត្រូវស្ថិតនៅក្រោមការចាត់ចែងនីតិវិធីបន្តដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដីស្របតាមច្បាប់បទប្បញ្ញត្តិពាក់ព័ន្ធ និងគោលការណ៍កំណត់របស់រាជរដ្ឋាភិបាល។

**មាត្រា៣៖**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤៖**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រីគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃច័ន្ទ ៦រោច ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៨ ខែមិថុនាឆ្នាំ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល៖</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៥៦០ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការតម្លើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១០៩អនក្រ.បក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១:** តម្លើងឋានន្តរស័ក្តិថ្នាក់ **វរសេនីយ៍ឯក** ជូននាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៖

| | | | | |
|---|---|---|---|---|
| ១- | វរសេនីយ៍ទោ | **យ៉ង់** | **សុខេម** | អត្តលេខ ០៧៦៤២ |
| ២- | វរសេនីយ៍ទោ | **ខិន** | **សសា** | អត្តលេខ ០៧៧១៩ |
| ៣- | វរសេនីយ៍ទោ | **អួន** | **ហៃ** | អត្តលេខ ០៧៧៦៥ |
| ៤- | វរសេនីយ៍ទោ | **ជា** | **ហេង** | អត្តលេខ ០៧៩៧២ |
| ៥- | វរសេនីយ៍ទោ | **ឈឹន** | **ធីន** | អត្តលេខ ០៨២០៦ |
| ៦- | វរសេនីយ៍ទោ | **ម៉េត** | **រ៉ានី** | អត្តលេខ ០៨២២៥ |
| ៧- | វរសេនីយ៍ទោ | **គោគ** | **សាវ៉ាន់** | អត្តលេខ ០៨៨៧៣ |
| ៨- | វរសេនីយ៍ទោ | **សំ** | **សិទ្ធី** | អត្តលេខ ០៨៩៥៨ |
| ៩- | វរសេនីយ៍ទោ | **កែវ** | **រតនា** | អត្តលេខ ០៨៩៨៣ |
| ១០- | វរសេនីយ៍ទោ | **ថោង** | **សាមិ** | អត្តលេខ ០៩០៤៤ |
| ១១- | វរសេនីយ៍ទោ | **ប្រាំង** | **ធីតា** | អត្តលេខ ០៩៥១៥ |

| | | | | |
|---|---|---|---|---|
| ១២- | វរសេនីយ៍ទោ | **យក់** | **សុវដេត** | អត្តលេខ ១០១៩៨ |
| ១៣- | វរសេនីយ៍ទោ | **ឌុច** | **ចំរើន** | អត្តលេខ ១១៦៧១ |
| ១៤- | វរសេនីយ៍ទោ | **ឈឹម** | **សារុន** | អត្តលេខ ១១៦៧៦ |
| ១៥- | វរសេនីយ៍ទោ | **ស្រី** | **សុជា** | អត្តលេខ ១១៦៧៩ |
| ១៦- | វរសេនីយ៍ទោ | **លី** | **មួយ** | អត្តលេខ ១១៨០៧ |
| ១៧- | វរសេនីយ៍ទោ | **ញ៉ៀម** | **ចាន់ថូ** | អត្តលេខ ១៥៦៦២ |
| ១៨- | វរសេនីយ៍ទោ | **ឈុំ** | **ថុន** | អត្តលេខ ១៥៨៣២ |
| ១៩- | វរសេនីយ៍ទោ | **ណុប** | **ធី** | អត្តលេខ ១៥៨៣៩ |
| ២០- | វរសេនីយ៍ទោ | **ហ៊ុល** | **វាសនា** | អត្តលេខ ១៩៦៨៤ |
| ២១- | វរសេនីយ៍ទោ | **រស់** | **ឌីទី** | អត្តលេខ ២២១១៩ |
| ២២- | វរសេនីយ៍ទោ | **ស៊ីុខ** | **ចាន់អូន** | អត្តលេខ ២៤៧០៥ |
| ២៣- | វរសេនីយ៍ទោ | **លី** | **គឹមលន់** | អត្តលេខ ២៤៧៣៥ |
| ២៤- | វរសេនីយ៍ទោ | **ផេង** | **សេង** | អត្តលេខ ២៤៧៨៤ |
| ២៥- | វរសេនីយ៍ទោ | **ឈួន** | **ចាន់ឡា** | អត្តលេខ ២៤៨៣៣ |
| ២៦- | វរសេនីយ៍ទោ | **ចាន់** | **ឧិត្យ** | អត្តលេខ ២៩០៧៣ |
| ២៧- | វរសេនីយ៍ទោ | **ម៉ៅ** | **រិទ្ធី** | អត្តលេខ ៣៦១៥០ |
| ២៨- | វរសេនីយ៍ទោ | **ព្រុំ** | **សារ៉ាត់** | អត្តលេខ ៤៩៨១២ |
| ២៩- | វរសេនីយ៍ទោ | **មាស** | **ម៉េងហួត** | អត្តលេខ ៥៤៩០១ |
| ៣០- | វរសេនីយ៍ទោ | **គួង** | **ផាន់តារា** | អត្តលេខ ៥៦៧៩៥ |
| ៣១- | វរសេនីយ៍ទោ | **ឡាយ** | **ឧត្តម** | អត្តលេខ ៥៧៤០១ |
| ៣២- | វរសេនីយ៍ទោ | **គូ** | **ចិន្តា** | អត្តលេខ ៦១៣៤២ |
| ៣៣- | វរសេនីយ៍ទោ | **ឃី** | **ជួន** | អត្តលេខ ៦២៤០៣ |
| ៣៤- | វរសេនីយ៍ទោ | **ស្រេង** | **ឆារី** | អត្តលេខ ៦៤១៩៦ |
| ៣៥- | វរសេនីយ៍ទោ | **ម៉ង់** | **ស៊ី** | អត្តលេខ ៦៤៦៦៥ |
| ៣៦- | វរសេនីយ៍ទោ | **ឡឿន** | **វ៉ាន់ឡឿន** | អត្តលេខ ៦៨៧៤៥ ។ |

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដែលមានចែងក្នុងមាត្រា ១ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*ថ្ងៃសុក្រ ១១ កើត ខែ ជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២*

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៨*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ** ៥១១ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការតម្លើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១០៩អនក្រ.បក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១:** តម្លើងឋានន្តរស័ក្តិថ្នាក់ **វរសេនីយ៍ឯក** ជូននាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៖

| | | | | |
|---|---|---|---|---|
| ១- | វរសេនីយ៍ទោ | **ជា** | **ស្តួញ** | អត្តលេខ ០៤២៥៩ |
| ២- | វរសេនីយ៍ទោ | **ហ៊ីន** | **ម៉ុនស៊ីដេត** | អត្តលេខ ០៤៣៣៨ |
| ៣- | វរសេនីយ៍ទោ | **ត្លូវ** | **សុវណ្ណា** | អត្តលេខ ០៤៤០៨ |
| ៤- | វរសេនីយ៍ទោ | **សូ** | **វណ្ណាធិន** | អត្តលេខ ០៤៧១២ |
| ៥- | វរសេនីយ៍ទោ | **ឃឹម** | **ស៊ាងហៃ** | អត្តលេខ ០៥៥៣២ |
| ៦- | វរសេនីយ៍ទោ | **លីវ** | **សេងហ៊ុម** | អត្តលេខ ០៨១៩២ |
| ៧- | វរសេនីយ៍ទោ | **ឈួរ** | **ម៉ាឌី** | អត្តលេខ ០៩៤៩៦ |
| ៨- | វរសេនីយ៍ទោ | **សួង** | **ស៊ិន** | អត្តលេខ ១១០០៨ |
| ៩- | វរសេនីយ៍ទោ | **ឌុក** | **ធីយ៉ា** | អត្តលេខ ១១១០៤ |

| | | | | |
|---|---|---|---|---|
| ១០- | វរសេនីយ៍ទោ | **នៅ** | **ឧុទ្ធា** | អត្តលេខ ១១៧៧៩ |
| ១១- | វរសេនីយ៍ទោ | **ឯម** | **រុន** | អត្តលេខ ១៤០៩១ |
| ១២- | វរសេនីយ៍ទោ | **នាង** | **ឌុធ** | អត្តលេខ ១៤១៤៧ |
| ១៣- | វរសេនីយ៍ទោ | **ប៊ុត** | **ប៊ុនធឿន** | អត្តលេខ ១៤៤៧៣ |
| ១៤- | វរសេនីយ៍ទោ | **រួន** | **យ៉េត** | អត្តលេខ ១៥២៤១ |
| ១៥- | វរសេនីយ៍ទោ | **ជួន** | **មឿន** | អត្តលេខ ១៥២៥៩ |
| ១៦- | វរសេនីយ៍ទោ | **យ៉ាន់** | **យុទ្ធី** | អត្តលេខ ១៥៣៥៣ |
| ១៧- | វរសេនីយ៍ទោ | **អ៊ឹម** | **ឃឿន** | អត្តលេខ ១៥៣៧៧ |
| ១៨- | វរសេនីយ៍ទោ | **សុខ** | **យ៉េន** | អត្តលេខ ១៥៦០៧ |
| ១៩- | វរសេនីយ៍ទោ | **ជា** | **ជួន** | អត្តលេខ ១៥៦១៦ |
| ២០- | វរសេនីយ៍ទោ | **ខ្លួត** | **សុឃា** | អត្តលេខ ១៦៤៥១ |
| ២១- | វរសេនីយ៍ទោ | **ឯក** | **ប៉ាន់ជន** | អត្តលេខ ១៩២៩៧ |
| ២២- | វរសេនីយ៍ទោ | **បេន** | **សំអាត** | អត្តលេខ ២២៤៣៩ |
| ២៣- | វរសេនីយ៍ទោ | **ឃុត** | **តិន** | អត្តលេខ ២៤១៤៧ |
| ២៤- | វរសេនីយ៍ទោ | **ផាន** | **ផល** | អត្តលេខ ២៤៦០៩ |
| ២៥- | វរសេនីយ៍ទោ | **សែម** | **ស៊ីថា** | អត្តលេខ ៤៩៣៥១ |
| ២៦- | វរសេនីយ៍ទោ | **ហួត** | **បូរី** | អត្តលេខ ៥៣៨១១ |
| ២៧- | វរសេនីយ៍ទោ | **ឆាង** | **ឡេង** | អត្តលេខ ៥៥៥៩៨ |
| ២៨- | វរសេនីយ៍ទោ | **ស** | **កែវពិសិដ្ឋ** | អត្តលេខ ៥៨១១៧ ។ |

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដែលមានចែងក្នុងមាត្រា ១ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*ថ្ងៃសុក្រ ១១កើត ខែ ភទ្របទ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស ២៥៦២*

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១៨*

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ...៥១៧...អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការផ្ទេរក្របខ័ណ្ឌ នាយទាហាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលតួនាទី ភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំង របស់អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា១ :** ផ្ទេរក្របខ័ណ្ឌ នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ជូនឧត្តមសេនីយ៍ត្រី **ចាយ ម្ញាណា** អត្តលេខ០៤៨០៧៣ នាយសេនាធិការរង បញ្ជាការដ្ឋានកាំភ្លើងធំ អគ្គបញ្ជាការដ្ឋាន បច្ចុប្បន្នទៅបម្រើការងារក្នុងក្របខ័ណ្ឌ ក្រសួង-មហាផ្ទៃ ។

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃ សុក្រ ១១ កើត ខែ ជេស្ឋ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស ២៥៦២
ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួលៈ**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខ:** ៥៧៣ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការផ្ទេរ និងតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិកម្ពុជា

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សម្រេច

**មាត្រា ១** ៖ តែងតាំងមុខតំណែងលោកវរសេនីយ៍ឯក **ឡុន អក្កដា** អត្តលេខ ៧២១៦៧ ជាអនុប្រធាននាយកដ្ឋានបុគ្គលិក ដែលមានឋានៈ និងបុព្វសិទ្ធិស្មើ **ប្រធាននាយកដ្ឋាន** ។

**មាត្រា ២** ៖ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដែលមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃ សុក្រ ១១ កើត ខែ ជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៥១៦ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមន្ត្រីរាជការ

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញអនុក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

**ស ម្រេ ច**

**មាត្រា ១** : តែងតាំងមន្ត្រីរាជការ ចំនួន ០៣ រូប នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដូចមានរាយនាមខាងក្រោម៖

| | | | |
|---|---|---|---|
| ១- | លោក | **សាន ផល្លា** | ជាអគ្គនាយករងនៃអគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌ ជំនួសឯកឧត្តម **យន់ ខៀន** ដែលបានចូលនិវត្តន៍ |
| ២- | លោកស្រី | **សេង ផាន់និត** | ជាអគ្គនាយករងនៃអគ្គនាយកដ្ឋានអាជ្ញាធរជាតិសំបូរព្រៃគុក |
| ៣- | លោក | **គីម ពីនន់** | ជាសាកលវិទ្យាធិការរងនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ។ |

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីជនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*ថ្ងៃសុក្រ ១១ កើត ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២*

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែ ឧសភា ឆ្នាំ ២០១៨*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច/ឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៧៨ សសរ

# សេចក្តីសម្រេច
# ស្តីពី
# ការកែសម្រួលសមាសភាពគណៈកម្មការបង្ក្រាបបទល្មើសនានា និងត្រួតពិនិត្យការពារការធ្វើនេសាទក្នុងដែនសមុទ្រខេត្តកោះកុង និងតាមបណ្តោយព្រំដែនសមុទ្រកម្ពុជា-ថៃ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញប្រកាសលេខ ០១ ប្រក ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៩ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីវិធានការគ្រប់គ្រង និងលុបបំបាត់ភាពអនាធិបតេយ្យក្នុងវិស័យព្រៃឈើ

-បានឃើញប្រកាសលេខ ០២ ប្រក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីវិធានការគ្រប់គ្រង និងលុបបំបាត់ភាពអនាធិបតេយ្យក្នុងវិស័យជលផល

-បានឃើញសេចក្តីសម្រេចលេខ ៧២សសរ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៩ ស្តីពីការបង្កើតគណៈកម្មការបង្ក្រាបបទល្មើសនានានិងត្រួតពិនិត្យការពារការធ្វើនេសាទក្នុងដែនសមុទ្រខេត្តកោះកុង

-យោងការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ ១ ៖** ត្រូវបានកែសម្រួលសមាសភាពគណៈកម្មការ ដើម្បីបង្ក្រាបបទល្មើសនានា និងត្រួតពិនិត្យការពារការធ្វើនេសាទក្នុងដែនសមុទ្រខេត្តកោះកុង និងតាមបណ្តោយព្រំដែនសមុទ្រកម្ពុជា- ថៃ ដែលមានសមាសភាពដូចខាងក្រោម ៖

១-លោកជំទាវ មិថុនា ភូថង អភិបាល នៃគណៈអភិបាលខេត្តកោះកុង ប្រធាន

២-ឯកឧត្តម **លី យ៉ុងផាត់** ទីប្រឹក្សាសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី អនុប្រធានអចិន្ត្រៃយ៍

៣-ឧត្តមសេនីយ៍ឯក **យឿង សុខុន** មេបញ្ជាការយោធភូមិភាគទី៣ អនុប្រធាន

៤-ឧត្តមនាវីឯក **ទៀ សុខា** មេបញ្ជាការរងកងទ័ពជើងទឹក អនុប្រធាន

៥-ឧត្តមសេនីយ៍ឯក **តេង សួន** ប្រធាននាយកដ្ឋាននគរបាលការពារព្រំដែនទឹក អនុប្រធាន

៦-លោក ពុំ សុថា នាយអធិការដ្ឋានរដ្ឋបាលជលផលសមុទ្រ អនុប្រធាន

៧-លោកមេបញ្ជាការតំបន់ប្រតិបត្តិការសឹករងខេត្តកោះកុង សមាជិក

៨-លោកមេបញ្ជាការកងរាជអាវុធហត្ថខេត្តកោះកុង សមាជិក

៩-លោកស្នងការនគរបាលខេត្តកោះកុង សមាជិក

១០-លោកប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកោះកុង សមាជិក

១១-លោកប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តកោះកុង សមាជិក

១២-លោកប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តកោះកុង សមាជិក

១៣-លោកប្រធានមន្ទីរពាណិជ្ជកម្មខេត្តកោះកុង សមាជិក

១៤-លោកប្រធានសាខាគយ និងរដ្ឋាករខេត្តកោះកុង សមាជិក

១៥-លោកប្រធានសាខាកាំកុងត្រូលប្រចាំខេត្តកោះកុង សមាជិក

**ប្រការ ២ ៖** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ខាងលើត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ១៥ រោច ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី

-ដូចប្រការ ២

-រាជកិច្ច

-ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ............សហវ.........

**ប្រកាសអន្តរក្រសួង**
**ស្តីពី**
**ការបង្កើតវិជ្ជាជីវៈគណនេយ្យករបម្រើប្រទាន សម្រាប់ឆ្នាំ២០១៨**
**នៅក្រសួងព័ត៌មាន**

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**រដ្ឋមន្ត្រី**
**ក្រសួងព័ត៌មាន**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/ន.ស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៧/០១៩ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨
- បានឃើញអនុក្រឹត្យលេខ៧០ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៩ ដែលស្តីពីការរៀបចំ និងប្រព្រឹត្តិទៅរបស់ក្រសួងព័ត៌មាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ: ៨៥៥-២៣-៤២៧ ៧៩៨
Phone: 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ១៩ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៤៤ មាត្រា៤៥ មាត្រា៤៦ និងមាត្រា៤៧ នៃអនុក្រឹត្យ លេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការរដ្ឋនៅតាមក្រសួង ខេត្ត-ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ០០៤ សហវ.ម. ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ១២១២ សហវ. ប្រក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនី នៃប្លង់គណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ៥២៣ សហវ. ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ច នៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ១៩៣៧ សហវ. ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- ប្រកាសលេខ៨២៩ សហវ. ប្រក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលប្រការ៤ ប្រការ៥ ប្រការ១៤ ប្រការ១៦ និងប្រការ១៧ នៃប្រកាសលេខ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- បានឃើញប្រកាសលេខ០៧៩ ព. ណ. គន ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការដាក់ឱ្យអនុវត្តអង្គភាពថវិកា
- យោងតាមតម្រូវការចាំបាច់នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងព័ត៌មាន

## សម្រេច

**ប្រការ១ .—**

ត្រូវបានបង្កើតរជ្ជទេយ្យបុរេប្រទានថវិកាកម្មវិធី ជំពូក៦០ "ការទិញ" និងជំពូក៦១ "សេវាកម្ម" នៅក្រសួងព័ត៌មាន សម្រាប់មុខសញ្ញាចំណាយដូចមានចែងក្នុងប្រការ៥ថ្មី នៃប្រកាសលេខ៨២៩ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលប្រការ៤ ប្រការ៥ ប្រការ១៤ ប្រការ១៦ និងប្រការ១៧ នៃប្រកាសលេខ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទាន សម្រាប់រដ្ឋបាលថ្នាក់ជាតិ។

តារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន ត្រូវបានកំណត់ជាឧបសម្ព័ន្ធ នៃប្រកាសអន្តរក្រសួងនេះ។

**ប្រការ២ .—**

ចំនួនទឹកប្រាក់មួយជុំបង្វិល នៃរជ្ជទេយ្យបុរេប្រទាន ត្រូវកំណត់ដូចក្នុងតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន។

**ប្រការ៣ .—**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤ .—**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងអគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន ប្រធាននាយកដ្ឋានទទួលបន្ទុករដ្ឋបាល និងហិរញ្ញវត្ថុរបស់ក្រសួងព័ត៌មាន ប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងព័ត៌មាន ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ១០រោច ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស ២៥៦១

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៨

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រី**
**ក្រសួងព័ត៌មាន**

**ខៀវ កាញារីទ្ធ**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងព័ត៌មាន

## តារាងឧបសម្ព័ន្ធវិធានការរៀបចំ ថវិកាកម្មវិធីឆ្នាំ២០១៨ របស់ក្រសួងព័ត៌មាន

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ២០១៨ | ឥណទាន ដែលជ្រើសរើស | ឥណទាន វិធានការរៀបចំ | ឥណទាន ទូទាត់ធម្មតា | ឥណទាន០១ដំបូង វិធានការរៀបចំ | ភាគរយ |
|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ = ២ - ៣ | ៥ = ៣ / ៤ ដំ | ៦ |
| | | | **សរុបរួម** | 30,914,000,000 | 10,022,000,000 | 1,777,666,000 | 8,234,334,000 | 444,416,500 | 18% |
| 60 | | | ការទិញ | 17,464,000,000 | 2,639,000,000 | 405,000,000 | 2,234,000,000 | 101,250,000 | 15% |
| | 6001 | | សម្ភារៈផ្គត់ផ្គង់ថែទាំ | 1,345,000,000 | 615,000,000 | 105,000,000 | 510,000,000 | 26,250,000 | 17% |
| | | 60011 | សម្ភារៈផ្គត់ផ្គង់ សម្អាត និងអនាម័យ | 5,000,000 | 5,000,000 | 5,000,000 | 0 | 1,250,000 | 100% |
| | | 60012 | សម្ភារៈផ្គត់ផ្គង់សម្រាប់ថែទាំអាគារ ប្រាសាទ និងសំណង់ផ្សេងៗ | 10,000,000 | 10,000,000 | 10,000,000 | 0 | 2,500,000 | 100% |
| | | 60014 | សម្ភារៈផ្គត់ផ្គង់សម្រាប់ថែទាំសម្ភារៈឧបករណ៍ | 600,000,000 | 600,000,000 | 90,000,000 | 510,000,000 | 22,500,000 | 15% |
| | | 60015 | ប្រេងឥន្ធនៈ និងប្រេងរំអិល | 730,000,000 | 0 | 0 | 0 | 0 | 0% |
| | 6002 | | សម្ភារៈផ្គត់ផ្គង់ផ្នែករដ្ឋបាល | 1,820,000,000 | 1,820,000,000 | 236,000,000 | 1,584,000,000 | 59,000,000 | 13% |
| | | 60021 | សម្ភារៈការិយាល័យ | 1,800,000,000 | 1,800,000,000 | 216,000,000 | 1,584,000,000 | 54,000,000 | 12% |
| | | 60022 | សៀវភៅមើល និងឯកសារ | 20,000,000 | 20,000,000 | 20,000,000 | 0 | 5,000,000 | 100% |
| | | 60023 | ការបោះពុម្ព | 0 | 0 | 0 | 0 | 0 | 0% |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | 6004 | | សំលៀកបំពាក់ និងការតុបតែង | 14,000,000 | 4,000,000 | 4,000,000 | 0 | 1,000,000 | 100% |
| | | 60041 | ឯកសណ្ឋាន | 4,000,000 | 4,000,000 | 4,000,000 | 0 | 1,000,000 | 100% |
| | | 60042 | សំលៀកបំពាក់ការពារសុវត្ថិភាព | 10,000,000 | 0 | 0 | 0 | 0 | 0% |
| | 6005 | | សម្ភារៈតូចតាច សង្ហារឹម និងសម្ភារៈបរិក្ខារ | 7,300,000,000 | 200,000,000 | 60,000,000 | 140,000,000 | 15,000,000 | 30% |
| | | 60051 | សម្ភារៈ និងបរិក្ខារបច្ចេកទេស | 3,500,000,000 | 0 | 0 | 0 | 0 | |
| | | 60052 | សង្ហារឹម | 700,000,000 | 0 | 0 | 0 | 0 | |
| | | 60053 | សម្ភារៈប្រើប្រាស់ | 200,000,000 | 200,000,000 | 60,000,000 | 140,000,000 | 15,000,000 | 30% |
| | | 60054 | សម្ភារៈ និងឧបករណ៍ដឹកជញ្ជូន | 900,000,000 | 0 | 0 | 0 | 0 | |
| | | 60055 | សម្ភារៈ និងឧបករណ៍ដឹកជញ្ជូន | 2,000,000,000 | 0 | 0 | 0 | 0 | |
| | 6006 | | ថាមពល និងទឹក | 6,985,000,000 | 0 | 0 | 0 | 0 | |
| | | 60061 | អគ្គិសនី | 6,885,000,000 | 0 | 0 | 0 | 0 | |
| | | 60062 | ទឹក | 100,000,000 | 0 | 0 | 0 | 0 | |
| 61 | | | សេវាកម្ម | 13,450,000,000 | 7,383,000,000 | 1,372,666,000 | 6,000,334,000 | 343,166,500 | 19% |
| | 6102 | | ការជួលមធ្យោបាយដឹកជញ្ជូន | 100,000,000 | 0 | 0 | 0 | 0 | 0% |
| | 6105 | | ការថែទាំ និងជួសជុល | 4,011,300,000 | 3,761,300,000 | 374,066,000 | 3,387,234,000 | 93,516,500 | 10% |
| | | 61052 | ការថែទាំ ជួសជុលអាគារផ្សេងៗ និងប្រាសាទ | 1,277,000,000 | 1,277,000,000 | 127,700,000 | 1,149,300,000 | 31,925,000 | 10% |
| | | 61053 | ការថែទាំ និងជួសជុលផ្លូវ ផ្លូវលំ ស្ពាន និងលូ | 250,000,000 | 0 | 0 | 0 | 0 | |
| | | 61054 | ការថែទាំបណ្តាញផ្សេងៗ | 690,000,000 | 690,000,000 | 103,500,000 | 586,500,000 | 25,875,000 | 15% |
| | | 61056 | ការថែទាំ និងជួសជុលមធ្យោបាយដឹកជញ្ជូន | 1,035,000,000 | 1,035,000,000 | 51,750,000 | 983,250,000 | 12,937,500 | 5% |
| | | 61057 | ការថែទាំ និងជួសជុលសម្ភារៈ និងឧបករណ៍បច្ចេកទេស | 536,300,000 | 536,300,000 | 64,356,000 | 471,944,000 | 16,089,000 | 12% |
| | | 61058 | ការថែទាំ និងជួសជុលផ្សេងៗ | 223,000,000 | 223,000,000 | 26,760,000 | 196,240,000 | 6,690,000 | 12% |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | 6107 | | សោហ៊ុយសិក្សាពិសោធន៍ សោហ៊ុយនៃការប្រើប្រាស់សេវា និង សោហ៊ុយនៃការប្រើប្រាស់សិទ្ធិ | 5,162,000,000 | 0 | 0 | 0 | 0 | |
| | | 61073 | សោហ៊ុយនៃការប្រើប្រាស់សិទ្ធិ | 5,162,000,000 | 0 | 0 | 0 | 0 | |
| | 6110 | | ទំនាក់ទំនងសាធារណៈ និងផ្សព្វផ្សាយ | 1,671,700,000 | 1,671,700,000 | 493,200,000 | 1,168,500,000 | 123,300,000 | 30% |
| | | 61101 | សោហ៊ុយទទួលភ្ញៀវជាតិ | 16,700,000 | 16,700,000 | 16,700,000 | 0 | 4,175,000 | 100% |
| | | 61102 | សោហ៊ុយទទួលភ្ញៀវបរទេស | 260,000,000 | 260,000,000 | 52,000,000 | 208,000,000 | 13,000,000 | 20% |
| | | 61103 | ប្រជុំ សិក្ខាសាលា និងសន្និសីទ | 1,140,000,000 | 1,140,000,000 | 342,000,000 | 798,000,000 | 85,500,000 | 30% |
| | | 61104 | ចំណាយរៀបចំពិធីបុណ្យ | 10,000,000 | | 0 | 0 | 0 | |
| | | 61105 | ចំណាយសម្រាប់វត្ថុអនុស្សាវរីយ៍នៅក្នុង និងក្រៅប្រទេស | 45,000,000 | 45,000,000 | 22,500,000 | 22,500,000 | 5,625,000 | 50% |
| | | 61107 | ការឃោសនា និងផ្សព្វផ្សាយព័ត៌មានសាធារណៈ | 200,000,000 | 200,000,000 | 60,000,000 | 140,000,000 | 15,000,000 | 30% |
| | 6111 | | ចំណាយលើការជាវសារព័ត៌មាន និងឯកសារ | 400,000,000 | 0 | 0 | 0 | 0 | #DIV/0! |
| | | 61118 | ចំណាយលើការជាវសារព័ត៌មាន និងឯកសារផ្សេងៗ | 400,000,000 | 0 | 0 | 0 | 0 | |
| | 6112 | | ចំណាយទូទាត់សោហ៊ុយក្នុងប្រទេស | 1,552,000,000 | 1,552,000,000 | 465,600,000 | 1,086,400,000 | 116,400,000 | 30% |
| | | 61121 | សោហ៊ុយដឹកជញ្ជូន | 51,000,000 | 51,000,000 | 15,300,000 | 35,700,000 | 3,825,000 | 30% |
| | | 61122 | សោហ៊ុយបេសកកម្ម | 272,000,000 | 272,000,000 | 81,600,000 | 190,400,000 | 20,400,000 | 30% |
| | | 61123 | សោហ៊ុយស្នាក់នៅ | 1,229,000,000 | 1,229,000,000 | 368,700,000 | 860,300,000 | 92,175,000 | 30% |
| | 6113 | | ចំណាយទូទាត់សោហ៊ុយក្រៅប្រទេស | 398,000,000 | 398,000,000 | 39,800,000 | 358,200,000 | 9,950,000 | 10% |
| | | 61131 | សោហ៊ុយដឹកជញ្ជូន | 150,000,000 | 150,000,000 | 15,000,000 | 135,000,000 | 3,750,000 | 10% |
| | | 61132 | សោហ៊ុយបេសកកម្ម | 98,000,000 | 98,000,000 | 9,800,000 | 88,200,000 | 2,450,000 | 10% |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | 61133 | សោហ៊ុយស្នាក់នៅ | 150,000,000 | 150,000,000 | 15,000,000 | 135,000,000 | 3,750,000 | 10% |
| | 6114 | | សោហ៊ុយប្រៃសណីយ៍ និងទូរគមនាគមន៍ | 155,000,000 | 0 | 0 | 0 | 0 | |
| | | 61141 | សោហ៊ុយប្រៃសណីយ៍ | 5,000,000 | 0 | 0 | 0 | 0 | |
| | | 61142 | សោហ៊ុយទូរគមនាគមន៍ | 150,000,000 | 0 | 0 | 0 | 0 | |

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី ខែ ឆ្នាំ២០១៨
ឯ.ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា
អគ្គនាយក នៃអគ្គនាយកដ្ឋានរតនាគារជាតិ

អគ្គនាយករង

មិញ បានសុវណ្ណអានិច្ចាសីលា

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី ខែ ឆ្នាំ២០១៨
ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា
អគ្គនាយក នៃអគ្គនាយកដ្ឋានថវិកា

កែ ច័ន្ទធាប៊ូរ៉ៈ

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី ខែ ឆ្នាំ២០១៨
អគ្គនាយក
អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

លី វ៉ាន់ហុង

ថ្ងៃទី ខែ ឆ្នាំ២០១៨
រដ្ឋលេខាធិការប្រុបប្រទាន

បានឃើញ និងឯកភាព
ថ្ងៃ ខែ ឆ្នាំច នព្វស័ក ព.ស ២៥៦១
ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ២០១៨
ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

បានឃើញ និងឯកភាព
ថ្ងៃ ខែមាឃ ឆ្នាំច នព្វស័ក ព.ស ២៥៦១
ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ខែកុម្ភៈ ឆ្នាំ២០១៨
រដ្ឋមន្ត្រី
ក្រសួងព័ត៌មាន

ខៀវ កាញារីទ្ធ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ [illegible] សហវ.[illegible]

# ប្រកាស
# ស្តីពី
## ការតែងតាំងគណនេយ្យករ
## ប្រចាំនៅវិទ្យាស្ថានជាតិសុខភាពសាធារណៈ នៃក្រសួងសុខាភិបាល

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែ ធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ន.ស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៣/០០៤ ចុះថ្ងៃទី២១ ខែមិនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធ្វើវិសោធនកម្មមាត្រា៩ និងមាត្រា១០ នៃច្បាប់ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ: ៨៥៥-២៣-៤២៧ ៧៩៨
Phone: 855-23-724 664 Fax : 855-23-427 798

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៣/០០៤ ចុះថ្ងៃទី២១ ខែមិនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធ្វើវិសោធនកម្មមាត្រា៩ និងមាត្រា១០នៃច្បាប់ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តិនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ១៣៩ អនក្រ.បក ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងថវិកា និងទ្រព្យសម្បត្តិរដ្ឋនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ៩១ អនក្រ.បក ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០០៦ ស្តីពីការប្រែក្លាយវិទ្យាស្ថានជាតិសុខភាពសាធារណៈ ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ១៩ អនក្រ.បក ចុះថ្ងៃទី០៣ ខែមិនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៤៤ មាត្រា៤៥ មាត្រា៤៦ និងមាត្រា៤៧ នៃអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
ចំនួនទឹកប្រាក់មួយជុំបង្វិលនៃរដ្ឋទេយ្យបុរេប្រទាន ត្រូវកំណត់ដូចតារាងឧបសម្ព័ន្ធរដ្ឋទេយ្យបុរេប្រទាន។

**ប្រការ៣**.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះត្រូវទុកជានិរាករណ៍។

**ប្រការ៤**.-

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃគ្រប់នាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និង អគ្គនាយកនៃអគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ និងក្រសួងបរិស្ថានត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះ ហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ១១រោច ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស ២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី១២ខែមីនា ឆ្នាំ២០១៨

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រី**
**ក្រសួងបរិស្ថាន**

**សាយ សំអាល់**

កន្លែងទទួល៖
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមុខងារសាធារណៈ
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
-ដូចប្រការ៤
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងបរិស្ថាន

តារាងឧបសម្ព័ន្ធរដ្ឋទេយ្យបុរេប្រទានថវិកាកម្មវិធីឆ្នាំ២០១៨
របស់អគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៨ | ឥណទានដែលត្រូវជ្រើសរើស | ឥណទានរដ្ឋទេយ្យបុរេប្រទាន | ឥណទានទូទាត់ធម្មតា | ឥណទាន០១ជុំបង្វិលរដ្ឋទេយ្យបុរេប្រទាន | ភាគរយ |
|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤=២-៣ | ៥=៣/៤ជុំ | ៦=៣/២ |
| | | | សរុបរួម | 2,192,500,000 | 1,033,000,000 | 311,640,000 | 721,360,000 | 77,910,000 | 30% |
| 60 | | | ការទិញ | 552,000,000 | 352,000,000 | 59,970,000 | 292,030,000 | 14,992,500 | 17% |
| | 6001 | | សម្ភារៈផ្គត់ផ្គង់ថែទាំ | 15,000,000 | 15,000,000 | 15,000,000 | | 3,750,000 | 100% |
| | | 60014 | សម្ភារៈផ្គត់ផ្គង់សម្រាប់ថែទាំសម្ភារៈឧបករណ៍ | 15,000,000 | 15,000,000 | 15,000,000 | | 3,750,000 | 100% |
| | 6002 | | សម្ភារៈផ្គត់ផ្គង់ផ្នែករដ្ឋបាល | 322,000,000 | 322,000,000 | 29,970,000 | 292,030,000 | 7,492,500 | 9% |
| | | 60021 | សម្ភារៈការិយាល័យ | 70,000,000 | 70,000,000 | 9,370,000 | 60,630,000 | 2,342,500 | 13% |
| | | 60023 | ការបោះពុម្ព | 252,000,000 | 252,000,000 | 20,600,000 | 231,400,000 | 5,150,000 | 8% |
| | 6005 | | សម្ភារៈតូចតាច សង្ហារឹម និងសម្ភារៈបរិក្ខារ | 215,000,000 | 15,000,000 | 15,000,000 | | 3,750,000 | 100% |
| | | 60052 | សង្ហារឹម | 15,000,000 | 15,000,000 | 15,000,000 | | 3,750,000 | 100% |
| | | 60055 | សម្ភារៈនិងបរិក្ខារបច្ចេកទេសព័ត៌មានវិទ្យា | 200,000,000 | | | | | 0% |
| 61 | | | សេវាកម្ម | 1,640,500,000 | 681,000,000 | 251,670,000 | 429,330,000 | 62,917,500 | 37% |
| | 6105 | | ការថែទាំនិងជួសជុល | 10,000,000 | 10,000,000 | 10,000,000 | | 2,500,000 | 100% |
| | | 61057 | ការថែទាំនិងជួសជុលសម្ភារៈ និងឧបករណ៍បច្ចេកទេស | 10,000,000 | 10,000,000 | 10,000,000 | | 2,500,000 | 100% |
| | 6107 | | សោហ៊ុយសិក្សាពិសោធន៍ និងប្រើប្រាស់សិទ្ធិ | 187,500,000 | | | | | 0% |
| | | 61073 | សោហ៊ុយនៃការប្រើប្រាស់សិទ្ធិ | 187,500,000 | | | | | 0% |
| | 6110 | | ទំនាក់ទំនងសាធារណៈនិងផ្សព្វផ្សាយ | 1,067,000,000 | 297,000,000 | 134,970,000 | 162,030,000 | 33,742,500 | 45% |
| | | 61103 | ប្រជុំ សិក្ខាសាលា និងសន្និសីទ | 297,000,000 | 297,000,000 | 134,970,000 | 162,030,000 | 33,742,500 | 45% |
| | | 61104 | ចំណាយរៀបចំពិធីបុណ្យ | 70,000,000 | | | | | 0% |
| | | 61107 | ការឃោសនានិងផ្សព្វផ្សាយព័ត៌មានសាធារណៈ | 700,000,000 | | | | | 0% |
| | 6112 | | ចំណាយទូទាត់សោហ៊ុយក្នុងប្រទេស | 284,000,000 | 284,000,000 | 81,100,000 | 202,900,000 | 20,275,000 | 29% |
| | | 61121 | សោហ៊ុយដឹកជញ្ជូន | 90,000,000 | 90,000,000 | 18,440,000 | 71,560,000 | 4,610,000 | 20% |
| | | 61122 | សោហ៊ុយបេសកកម្ម | 50,000,000 | 50,000,000 | 10,680,000 | 39,320,000 | 2,670,000 | 21% |
| | | 61123 | សោហ៊ុយស្នាក់នៅ | 144,000,000 | 144,000,000 | 51,980,000 | 92,020,000 | 12,995,000 | 36% |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| 6113 | | ចំណាយទូទាត់សោហ៊ុយក្នុងប្រទេស | 90,000,000 | 90,000,000 | 25,600,000 | 64,400,000 | 6,400,000 | 28% |
| | 61131 | សោហ៊ុយដឹកជញ្ជូន | 20,000,000 | 20,000,000 | 6,000,000 | 14,000,000 | 1,500,000 | 30% |
| | 61132 | សោហ៊ុយបេសកកម្ម | 40,000,000 | 40,000,000 | 6,000,000 | 34,000,000 | 1,500,000 | 15% |
| | 61133 | សោហ៊ុយស្នាក់នៅ | 30,000,000 | 30,000,000 | 13,600,000 | 16,400,000 | 3,400,000 | 45% |
| 6114 | | សោហ៊ុយប្រៃសណីយ៍និងទូរគមនាគមន៍ | 2,000,000 | | | | | 0% |
| | 61141 | សោហ៊ុយប្រៃសណីយ៍ | 2,000,000 | | | | | 0% |

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃ... ខែ... ឆ្នាំ... នព្វស័ក ព.ស ២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី... ខែ... ឆ្នាំ២០១៨
ប. ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា
អគ្គនាយក
អគ្គនាយកដ្ឋានរតនាគារជាតិ
**អគ្គនាយករង**
**មិញ្ញ បានសុវណ្ណអានិច្ចាសីលា**

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃ... ៦រោច ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែកុម្ភៈ ឆ្នាំ២០១៨
ប្រធានក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ
អមក្រសួងបរិស្ថាន
**ពៅ_ម៉េងហ៊ាង**

បានឃើញ និងឯកភាព
ថ្ងៃ... ខែ... ឆ្នាំរកា នព្វស័ក ព.ស ២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី... ខែ... ឆ្នាំ២០១៨
ឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
**បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

ថ្ងៃច័ន្ទ ៦កើត ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី២២ ខែមករា ឆ្នាំ២០១៨
រដ្ឋលេខាធិការប្រធានអង្គភាពលទ្ធកម្ម

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃច័ន្ទ ៦កើត ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែមករា ឆ្នាំ២០១៨
នាយកដ្ឋានរដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ
**លី សុខាភិរម្យ**

បានឃើញ និងឯកភាព
ថ្ងៃច័ន្ទ ៦កើត ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី២២ ខែមករា ឆ្នាំ២០១៨
**អគ្គនាយកចំណេះដឹង និងព័ត៌មានបរិស្ថាន**
**វេជ្ជ. ខិន_លីណា**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ...... សហវ......

ប្រកាសអន្តរក្រសួង
ស្តីពី
ការបង្កើតរង្វាន់លើកទឹកចិត្តបុគ្គលិកសម្រាប់ឆ្នាំ២០១៨
របស់អធិការដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នៃក្រសួងអប់រំ យុវជន និងកីឡា

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

រដ្ឋមន្ត្រី
ក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែ ធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញ បន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ន.ស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងអប់រំយុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែ តុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ១៩ អនក្រ.បក ចុះថ្ងៃទី០៣ ខែមិនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៤៤ មាត្រា៤៥ មាត្រា ៤៦ និងមាត្រា ៤៧ នៃអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៧ /០១៩ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិកានៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ១២១២ សហវ.ប្រក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- ប្រកាសលេខ៨២៩ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលប្រការ៤ ប្រការ៥ ប្រការ ១៤ ប្រការ១៦ និងប្រការ១៧ នៃប្រកាសលេខ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- បានឃើញប្រកាសអន្តរក្រសួងលេខ ១៩៤ សហវ.ប្រក ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ២០១៦ ស្តីពីការដាក់ឱ្យអនុវត្តអង្គភាពថវិកា
- យោងតាមតម្រូវការចាំបាច់នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអធិការដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នៃក្រសួងអប់រំយុវជន និងកីឡា

## សម្រេច

**ប្រការ១.**

ត្រូវបានបង្កើតរជ្ជទេយ្យបុរេប្រទានថវិកាកម្មវិធី ជំពូក៦០"ការទិញ" ជំពូក៦១"សេវាកម្ម" នៅអធិការដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នៃក្រសួងអប់រំ យុវជន និងកីឡា សម្រាប់មុខសញ្ញាចំណាយដូចមានចែងក្នុងប្រការ៥ថ្មី នៃប្រកាសលេខ៨២៩ សហវ.ប្រក ចុះថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលប្រការ៤ ប្រការ៥ ប្រការ១៤ ប្រការ១៦ និងប្រការ១៧ នៃប្រកាសលេខ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាម រជ្ជទេយ្យបុរេប្រទាន សម្រាប់រដ្ឋបាលថ្នាក់ជាតិ ។

តារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន ត្រូវបានកំណត់ជាឧបសម្ព័ន្ធនៃប្រកាសនេះ ។

**ប្រការ២ ._**

ចំនួនទឹកប្រាក់មួយជុំបង្វិលនៃរង្វាន់ទេយ្យបុរេប្រទាន ត្រូវកំណត់ដូចក្នុងតារាងឧបសម្ព័ន្ធរង្វាន់ទេយ្យបុរេប្រទាន ។

**ប្រការ៣ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៤ ._**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយក នៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការ នៃអគ្គាធិការដ្ឋាន និងអធិការដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ១១ រោច ខែ ផល្គុន ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ មីនា ឆ្នាំ២០១៨

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

បណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រី**
**ក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ ជួន ណារ៉ុន**

**កន្លែងទទួល**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមុខងារសាធារណៈ
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-ដូចប្រការ៤
-រាជកិច្ច
-ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
អង្គភាពថវិកាអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

## តារាងឧបសម្ព័ន្ធវិភាជន៍ឥណទានបុរេប្រទាន

## ថវិកាកម្មវិធីឆ្នាំ២០១៨ របស់អង្គភាពថវិកាអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

ឯកតា: រៀល

| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណាយ | ច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៨ | ឥណទានដែលជ្រើសរើស | ឥណទានផ្ទេរជាបុរេប្រទាន | ឥណទានខ្ទាត់ធម្មតា | ឥណទានទទួលបង្វិលផ្ទេរជាបុរេប្រទាន | ភាគរយ |
|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ =២-៣ | ៥ = ៣/៤ជុំ | ៦=៣/២ |
| សរុបរួមចំណាយថវិកា | | | | 609,500,000 | 571,700,000 | 384,200,000 | 187,500,000 | 96,050,000 | 67.20% |
| 60 | | | ការទិញ | 103,100,000 | 72,400,000 | 35,700,000 | 36,700,000 | 8,925,000 | 49.31% |
| | 6001 | | សម្ភារផ្គត់ផ្គង់ថែទាំ | 11,600,000 | 11,600,000 | 9,600,000 | 2,000,000 | 2,400,000 | 82.76% |
| | | 60011 | សម្ភារផ្គត់ផ្គង់សម្អាត និងអនាម័យ | 2,200,000 | 2,200,000 | 2,200,000 | - | 550,000 | 100.00% |
| | | 60014 | សម្ភារផ្គត់ផ្គង់សម្រាប់ថែទាំសម្ភារឧបករណ៍ | 6,000,000 | 6,000,000 | 4,000,000 | 2,000,000 | 1,000,000 | 66.67% |
| | | 60015 | ប្រេងឥន្ធនៈ និងប្រេងរំអិល | 3,400,000 | 3,400,000 | 3,400,000 | - | 850,000 | 100.00% |
| | 6002 | | សម្ភារផ្គត់ផ្គង់ផ្នែករដ្ឋបាល | 25,700,000 | 25,700,000 | 15,100,000 | 10,600,000 | 3,775,000 | 58.75% |
| | | 60021 | សម្ភារការិយាល័យ | 24,600,000 | 24,600,000 | 14,000,000 | 10,600,000 | 3,500,000 | 56.91% |
| | | 60022 | សៀវភៅមើល និងឯកសារ | 800,000 | 800,000 | 800,000 | - | 200,000 | 100.00% |
| | | 60023 | ការបោះពុម្ព | 300,000 | 300,000 | 300,000 | - | 75,000 | 100.00% |
| | 6003 | | ស្បៀងអាហារ និងផលិតផលកសិកម្ម | 2,400,000 | 2,400,000 | 2,400,000 | - | 600,000 | 100.00% |
| | | 60031 | ស្បៀង | 600,000 | 600,000 | 600,000 | - | 150,000 | 100.00% |
| | | 60037 | ស្បៀងសម្រាប់រដ្ឋបាល | 1,800,000 | 1,800,000 | 1,800,000 | - | 450,000 | 100.00% |
| | 6005 | | សម្ភារតូចតាច សម្លៀកបំពាក់ និងសម្ភារបរិក្ខារ | 63,400,000 | 32,700,000 | 8,600,000 | 24,100,000 | 2,150,000 | 26.30% |
| | | 60051 | សម្ភារនិងបរិក្ខារបច្ចេកទេសមិនមែនព័ត៌មានវិទ្យា | 1,800,000 | - | - | - | - | #DIV/0! |
| | | 60052 | សម្លៀកបំពាក់ | 8,900,000 | - | - | - | - | #DIV/0! |
| | | 60053 | សម្ភារប្រើប្រាស់ | 1,500,000 | 1,500,000 | 1,500,000 | - | 375,000 | 100.00% |
| | | 60054 | សម្ភារ និងឧបករណ៍ដឹកជញ្ជូន | 20,000,000 | - | - | - | - | #DIV/0! |
| | | 60055 | សម្ភារនិងបរិក្ខារបច្ចេកទេសព័ត៌មានវិទ្យា | 31,200,000 | 31,200,000 | 7,100,000 | 24,100,000 | 1,775,000 | 22.76% |
| 61 | | | សេវាកម្ម | 506,400,000 | 499,300,000 | 348,500,000 | 150,800,000 | 87,125,000 | 69.80% |
| | 6105 | | ការថែទាំនិងជួសជុល | 21,300,000 | 20,900,000 | 10,000,000 | 10,900,000 | 2,500,000 | 47.85% |
| | | 61052 | ការថែទាំ ជួសជុលអគារផ្សេងៗ និងប្រាសាទ | 400,000 | - | - | - | - | #DIV/0! |
| | | 61054 | ការថែទាំបណ្ដាញផ្សេងៗ | 3,200,000 | 3,200,000 | 1,200,000 | 2,000,000 | 300,000 | 37.50% |
| | | 61056 | ការថែទាំ និងជួសជុលមធ្យោបាយដឹកជញ្ជូន | 10,000,000 | 10,000,000 | 5,000,000 | 5,000,000 | 1,250,000 | 50.00% |
| | | 61057 | ការថែទាំនិងជួសជុលសម្ភារ និងឧបករណ៍បច្ចេកទេស | 7,700,000 | 7,700,000 | 3,800,000 | 3,900,000 | 950,000 | 49.35% |
| | 6108 | | សោហ៊ុយដឹកជញ្ជូន | 600,000 | - | - | - | - | #DIV/0! |
| | | 61081 | សម្ភារ និងទំនិញ | 600,000 | - | - | - | - | #DIV/0! |
| | 6110 | | ទំនាក់ទំនងសាធារណៈ និងផ្សព្វផ្សាយ | 26,900,000 | 26,900,000 | 26,900,000 | - | 6,725,000 | 100.00% |
| | | 61101 | សោហ៊ុយទទួលភ្ញៀវជាតិ | 600,000 | 600,000 | 600,000 | - | 150,000 | 100.00% |
| | | 61103 | ប្រជុំ សិក្ខាសាលា និងសន្និសីទ | 26,300,000 | 26,300,000 | 26,300,000 | - | 6,575,000 | 100.00% |
| | 6111 | | សារព័ត៌មាន និងឯកសារ | 1,100,000 | 1,100,000 | 600,000 | 500,000 | 150,000 | 54.55% |
| | | 61111 | ចំណាយលើការជាវសារព័ត៌មាន | 1,100,000 | 1,100,000 | 600,000 | 500,000 | 150,000 | 54.55% |
| | 6112 | | សោហ៊ុយបេសកកម្មក្នុងប្រទេស | 450,400,000 | 450,400,000 | 311,000,000 | 139,400,000 | 77,750,000 | 69.05% |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | 61121 | សោហ៊ុយដឹកជញ្ជូន | 58,000,000 | 58,000,000 | 40,100,000 | 17,900,000 | 10,025,000 | 69.14% |
| | | 61122 | សោហ៊ុយបេសកកម្ម | 54,900,000 | 54,900,000 | 38,000,000 | 16,900,000 | 9,500,000 | 69.22% |
| | | 61123 | សោហ៊ុយស្នាក់នៅ | 337,500,000 | 337,500,000 | 232,900,000 | 104,600,000 | 58,225,000 | 69.01% |
| | 6113 | | **សោហ៊ុយបេសកកម្មក្រៅប្រទេស** | **4,000,000** | - | - | - | - | **#DIV/0!** |
| | | 61132 | សោហ៊ុយបេសកកម្ម | 4,000,000 | - | - | - | - | #DIV/0! |
| | 6114 | | **សោហ៊ុយប្រៃសណីយ៍ និងទូរគមនាគមន៍** | **2,100,000** | - | - | - | - | **#DIV/0!** |
| | | 61142 | សោហ៊ុយទូរគមនាគមន៍ | 2,100,000 | - | - | - | - | #DIV/0! |

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ២០១៨
ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា
អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ
**អគ្គនាយករង**
**មុំញ ប្បានសុវណ្ណអានិច្ចាសីលា**

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី ៣០ ខែ [illegible] ឆ្នាំ២០១៨
ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា
អគ្គនាយកអគ្គនាយកដ្ឋានថវិកា
ប្រធានក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ
អមក្រសួងអប់រំ យុវជន និងកីឡា
**គិន_កោសល្ល**

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១៨
អធិការនៃ
អធិការដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
**ប៉ោ_សំអាង**

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី[illegible] ខែ [illegible] ឆ្នាំ២០១៨
រដ្ឋលេខាធិការប្រចាំការ
**ចាន់ សារ៉េត**

បានឃើញ និងឯកភាព
ថ្ងៃ [illegible] ខែ[illegible] ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១៨
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
**បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

បានឃើញ និងឯកភាព
ថ្ងៃ [illegible] ខែ [illegible] ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ [illegible] ឆ្នាំ២០១៨
រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា
**បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
Kingdom of Cambodia
Nation Religion King

**ក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
Ministry of Industry & Handicraft
លេខ : ០៤៤ ឧស្សា.ក.ស្រ.ឧសក.០១

ថ្ងៃ ព្រហស្បតិ៍ ៤កើត ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែមករា ឆ្នាំ២០១៨

## ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញសំណើសុំប្រកាសបង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៧ របស់ក្រុមហ៊ុន ស្វែល ហ្គាម៉ិន (ខេមបូឌា) ឯ.ក

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន ស្វែល ហ្គាម៉ិន (ខេមបូឌា) ឯ.ក (SWELL GARMENT (CAMBODIA) CO., LTD.) តំណាងដោយលោក WU SHENGHONG បង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ ដែលមានទីតាំងស្ថិតនៅ ភូមិឫស្សី សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥) -២៣-២១១១៤១ , ទូរសារ : (៨៥៥) -២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141, Fax: 855-23-428263

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| សម្លៀកបំពាក់ | ១៤១០ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកផ្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្ដីណែនាំស្ដីពីការដាក់ឈ្មោះ រោងចក្រ និងសិប្បកម្ម។

**ផ្លាកឈ្មោះរោងចក្រ៖** " រោងចក្រកាត់ដេរសម្លៀកបំពាក់ ស្វែល ហ្គាម៉ិន (ខេមបូឌា) ឯ.ក "

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងបទបញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្ដើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព ០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម លើការផ្លាស់ប្ដូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្ដូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្ដូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ស្ដីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣ មាត្រា១៨ នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណី ប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ស្របតាមមាត្រា៥ នៃច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្ដល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្ដាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ស្របតាមមាត្រា១៩ នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣នៃច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម រយៈពេល ០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណី រោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល ០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និង តាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តិនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការ រៀងៗខ្លួន។

**ប្រការ១៥៖** ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

រដ្ឋលេខាធិការ

ហេង សុខគង់

ចម្លងជូន៖
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងបរិស្ថាន
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-សាលារាជធានីភ្នំពេញ
-មន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានីភ្នំពេញ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤ "ដើម្បីអនុវត្ត"
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ : ០៤៥៤ ឧសក.ពរ.ប្រក/អគ១

ថ្ងៃ.......................... ខែ............. ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី...... ខែ.......... ឆ្នាំ២០១៨

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញសំណើសុំប្រកាសបង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៧ របស់ក្រុមហ៊ុន វ៉ាន ជៀ ហាវ នីតធីង ឯ.ក

## សម្រេច

**ប្រការ១:** អនុញ្ញាតឱ្យក្រុមហ៊ុន វ៉ាន ជៀ ហាវ នីតធីង ឯ.ក (WAN JIA HAO KNITTING CO., LTD.) តំណាងដោយ លោកស្រី **SUN, WANFANG** បង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ ដែលមានទីតាំងស្ថិតនៅ តំបន់សេដ្ឋកិច្ចពិសេសតាយសេងបាវិត (សង្កាត់ប្រកម្មស ក្រុងបាវិត ខេត្តស្វាយរៀង)។

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥)-២៣-២១១១៤១ , ទូរសារ : (៨៥៥)-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141, Fax: 855-23-428263

| **ឈ្មោះផលិតផល** | **លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម** ISIC Rev.4 Code |
|---|---|
| សម្លៀកបំពាក់ | ១៤១០ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកផ្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្ដីណែនាំស្ដីពីការដាក់ឈ្មោះ រោងចក្រ និងសិប្បកម្ម។

**ផ្លាកឈ្មោះរោងចក្រ៖** " រោងចក្រកាត់ដេរសម្លៀកបំពាក់ វ៉ាន ជៀ ហាវ នីតធីង ឯ.ក "

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងបទបញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្ដើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព ០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម លើការផ្លាស់ប្ដូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្ដូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្ដូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ស្ដីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣ មាត្រា១៨ នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណី ប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ស្របតាមមាត្រា៥ នៃច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្ដល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្ដាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ស្របតាមមាត្រា១៩ នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣នៃច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម រយៈពេល ០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណី រោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល ០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និង តាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តិនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តស្វាយរៀង និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការ រៀងៗខ្លួន។

**ប្រការ១៥៖** ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម
រដ្ឋលេខាធិការ

ហេង សុខគង់

ចម្លងជូន៖
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងបរិស្ថាន
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- សាលាខេត្តស្វាយរៀង
- មន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តស្វាយរៀង
  "ដើម្បីជូនជ្រាប"
- ដូចប្រការ១៤ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
Kingdom of Cambodia
Nation Religion King

**ក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
Ministry of Industry & Handicraft
លេខ : ០៣៧.ឧស.ករ.ប្រក.០១

ថ្ងៃអង្គារ ១៤ កើត ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែមករា ឆ្នាំ២០១៨

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញសំណើសុំប្រកាសបង្កើតរោងចក្រផលិតក្តារប៉ាកេ ក្តារបន្ទះ និងគ្រឿងសង្ហារឹម ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៧ របស់ក្រុមហ៊ុន អិលប៊ី វូដ (ខេមបូឌា) ឯ.ក ។

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន អិលប៊ី វូដ (ខេមបូឌា) ឯ.ក (LB WOOD (CAMBODIA) CO., LTD.) តំណាងដោយ លោក **ZHANG CHI** បង្កើតរោងចក្រផលិតក្តារប៉ាកេ ក្តារបន្ទះ និងគ្រឿងសង្ហារឹម ដែលមានទីតាំងស្ថិតនៅ តំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ (ភូមិពូធឿង ឃុំបិតត្រាំង និងភូមិស្មាច់ដែង ឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ) ។

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥)-២៣-២១១១៤១ , ទូរសារ : (៨៥៥)-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh. Phone : 855-23-211141, Fax: 855-23-428263

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| ១- ក្ដារប៉ាកេ និងក្ដារបន្ទះ | ១៦២១ |
| ២- គ្រឿងសង្ហារឹម | ៣១០០ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកផ្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្ដីណែនាំស្ដីពីការដាក់ឈ្មោះ រោងចក្រ និងសិប្បកម្ម។

**ផ្លាកឈ្មោះរោងចក្រ៖** "រោងចក្រផលិតក្ដារប៉ាកេ ក្ដារបន្ទះ និងគ្រឿងសង្ហារឹម អិលប៊ី វូដ (ខេមបូឌា) ឯ.ក"

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងបទបញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្ដើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព ០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម លើការផ្លាស់ប្ដូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្ដូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្ដូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ស្ដីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣ មាត្រា១៨ នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណី ប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ស្របតាមមាត្រា៥ នៃច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្ដល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្ដាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ស្របតាមមាត្រា១៩ នៃច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រង រោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣នៃច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្ដីពីវិសោធនកម្មច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។ ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឱ្យបានទាប់ហេតុអំពីករណីប្រែប្រួល ហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាម មាត្រា៤១ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម រយៈពេល ០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណី រោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល ០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និង តាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តិនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តព្រះសីហនុ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការ រៀងៗខ្លួន។

**ប្រការ១៥៖** ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម
រដ្ឋលេខាធិការ

ហេង សុខគង់

ចម្លងជូន៖
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងបរិស្ថាន
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-សាលាខេត្តព្រះសីហនុ
-មន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តព្រះសីហនុ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤ "ដើម្បីអនុវត្ត"
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

រក្សាសិទ្ធ និងបោះពុម្ពដោយ
អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
នៃ ទីស្តីការគណៈរដ្ឋមន្ត្រី